ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាព
# ស្តីពី
# ការអប់រំបរិយាបន្ន
# ឆ្នាំ២០១៩-២០២៣

ឆ្នាំ២០១៩

# អារម្ភកថា

គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ត្រូវបានអនុម័តនៅខែមិថុនា ឆ្នាំ២០១៨ ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនមានពិការភាព។ ការកសាងផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្ន មានគោលបំណងផ្តល់ការចង្អុលទិសច្បាស់លាស់មួយដល់អ្នកពាក់ព័ន្ធសម្រាប់ការធ្វើកំណែទម្រង់ជាប្រព័ន្ធ ក៏ដូចជាសម្រាប់ការអនុវត្តផែនការសកម្មភាពដោយបញ្ចូលសកម្មភាព សូចនាករ ចំណុចដៅ ក្របខណ្ឌពេលវេលា អង្គភាពដឹកនាំ ស្ថាប័នគាំទ្រ ប្រភពថវិកា និងការពិនិត្យតាមដានវាយតម្លៃ សម្រាប់អនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ ផែនការសកម្មភាពនេះមានគោលបំណងផ្តល់ផែនទីចង្អុលផ្លូវ សម្រាប់ជួយជនស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូបឱ្យទទួលបានការអប់រំដែលមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត បណ្តុះការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទាពេញលេញ ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ និងធានាការចូលរួម ការប្តេជ្ញាចិត្ត និងការផ្តល់ចក្ខុវិស័យរួមពីគ្រប់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍទាំងអស់។

ផែនការសកម្មភាពអប់រំបរិយាបន្នគាំទ្រដល់ការផ្តួចផ្តើមរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានវិសាលភាពគ្របដណ្តប់ការអប់រំបរិយាបន្នសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ឆ្លើយតបទៅនឹងនិន្នាការអប់រំក្នុងតំបន់ និងសកលលោក ដោយរក្សាបរិបទអប់រំ និងវប្បធម៌របស់ប្រទេសកម្ពុជា ហើយឈានទៅសម្រេចផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣។ គោលដៅរួមនៃគោលនយោបាយអប់រំបរិយាបន្ន និងផែនការសកម្មភាពត្រូវធានាឱ្យបាននូវសិទ្ធិរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសក្នុងការទទួលបានការអប់រំដ៏សមស្រប និងការគាំទ្រចាំបាច់ដែលអាចជួយជនទាំងនោះ ឱ្យក្លាយខ្លួនទៅជាពលរដ្ឋកម្ពុជាប្រកបដោយផលិតភាពក្នុងការសម្រេចបាននូវសក្តានុពលជាអតិបរមា។ លទ្ធផលរំពឹងទុកនៃគោលនយោបាយអប់រំបរិយាបន្ន និងផែនការសកម្មភាពមាន៖

- ការបង្កើនការចុះឈ្មោះចូលរៀនរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសនៅតាមសាលារៀន ដោយលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ កំណត់អត្តសញ្ញាណជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុង និងក្រៅសាលារៀន និងផ្តល់ការគាំទ្រសមស្របចាំបាច់តាមបែបបច្ចេកវិទ្យា ដើម្បីឱ្យមានលទ្ធភាពចូលរៀន។
- ការបង្កើនសមត្ថភាពតាមស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំជនស្ថិតក្នុងសេចក្តីត្រូវការពិសេស តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន ការបង្កើតមជ្ឈដ្ឋានអប់រំសមរម្យ និងការកែប្រែការបង្រៀន និងកម្មវិធីសិក្សាឱ្យបានសមស្រប។

ក្រសួងអប់រំ យុវជន និងកីឡាសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ សហគមន៍ និងដៃគូអភិវឌ្ឍនានាចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការសកម្មភាពនេះ។ នាយកដ្ឋានពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ឱ្យបានសមស្របដោយផ្អែកលើផែនការសកម្មភាព ឆ្នាំ២០១៩-២០២៣ តាមរយៈកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងសហគមន៍ក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីអនុវត្តកម្មវិធីអប់រំជនស្ថិតក្នុងសេចក្តីត្រូវការពិសេសប្រកបដោយជោគជ័យនិងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ៧រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# មាតិកា


១.សាវតារ ....................................................................2
១.១. ស្ថានភាព និងបញ្ហាអាទិភាព ....................................................2
១.២. ចក្ខុវិស័យ ....................................................................4
១.៣. គោលបំណង ....................................................................4
២.គោលដៅ ....................................................................4
៣.យុទ្ធសាស្ត្រ ....................................................................4
៣.១. វិសាលភាព ....................................................................4
៣.២. យុទ្ធសាស្ត្រសំខាន់ៗ ....................................................................5
៤ .សង្ខេបសកម្មភាពសំខាន់ៗ ....................................................................5
៥ .ផែនការសកម្មភាព ....................................................................7
យុទ្ធសាស្ត្រ ៥.១. ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ....................................................................7
យុទ្ធសាស្ត្រ ៥.២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ ....................................................................9
យុទ្ធសាស្ត្រ ៥.៣ . អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន ....................................................................12
យុទ្ធសាស្ត្រ ៥.៤. ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌ ....................................................................16
យុទ្ធសាស្ត្រ ៥.៥. ជានាឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស ....................................................................28
យុទ្ធសាស្ត្រ ៥.៦. អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យស្អាត ....................................................................32
យុទ្ធសាស្ត្រ ៥.៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន ....................................................................35
យុទ្ធសាស្ត្រ៥.៨. លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន ....................................................................39
យុទ្ធសាស្ត្រ ៥.៩. ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ....................................................................42
៦. សរុបចំណាយតាមយុទ្ធសាស្ត្រ ....................................................................45
៧.ការចំណាយ ....................................................................45
៨.ការត្រួតពិនិត្យ និងការវាយតម្លៃ ....................................................................46
៩. សេចក្តីសន្និដ្ឋាន ....................................................................46
ពាក្យបំព្រួញ ....................................................................47
សន្ធានុក្រម ....................................................................48

## ១.សាវតារ

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយស្តីពីការអប់រំបរិយាបន្ន នាខែមិថុនា ឆ្នាំ២០១៨។ គោលនយោបាយនេះមានចក្ខុវិស័យក្នុងការធានាបាននូវការគោរពសិទ្ធិជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។ ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្ន បានដាក់ចេញនូវសកម្មភាពរយៈពេលវែង និងរយៈពេលមធ្យម សម្រាប់អនុវត្តរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់២០២៣។

### ១.១. ស្ថានភាព និងបញ្ហាអាទិភាព

នៅក្នុងពិភពលោក មានជនមានពិការភាពប្រមាណជាង១ពាន់លាននាក់ ក្នុងនោះជនមានពិការភាពចំនួន២០០លាននាក់កំពុងប្រឈមនឹងជីវភាពរស់នៅដោយលំបាក។ នៅប៉ុន្មានឆ្នាំខាងមុខ បញ្ហាពិការភាពនឹងក្លាយជាក្តីបារម្ភកាន់តែធំធេង ដោយសារអត្រាពិការភាពកាន់តែកើនឡើង ដែលបណ្តាលមកពីជំងឺរ៉ាំរ៉ៃផ្សេងៗ ដូចជា ទឹកនោមផ្អែម មហារីក ជំងឺសរសៃឈាមបេះដូង និងដាច់សរសៃឈាមក្នុងខួរក្បាលជាដើម។ កត្តានេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយទាន់ពេលវេលា។

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សបានបញ្ជាក់ថា មនុស្សទាំងអស់កើតមកមានសិទ្ធិសេរីភាព សមភាព និងសេចក្តីថ្លៃថ្នូរ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការដើម្បីធានាថា ជនមានពិការភាពក៏ដូចជាមនុស្សជាតិទាំងអស់ត្រូវទទួលបានសិទ្ធិដូចគ្នារួមមាន សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយសិទ្ធិសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ ដោយគ្មានការបែងចែក និងរើសអើង។ តំបន់អាស៊ី និងប៉ាស៊ីហ្វិក មានជនមានពិការភាពប្រមាណ៦៥០លាននាក់ ស្មើនឹង១៥% នៃប្រជាជនសរុប ដែលកំពុងត្រូវបានបំភ្លេច ឬមើលរំលង។ ឆ្លើយតបនឹងបញ្ហានេះ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (២០១៣-២០២២) បានចេញសេចក្តីប្រកាសទីក្រុងអ៊ីនឈាន់ និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមាន គុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ សេចក្តីប្រកាសនេះ បានកំណត់ចក្ខុវិស័យអប់រំឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងផ្តោតលើការអប់រំបែបបរិយាបន្ន សមធម៌ សំដៅផ្តល់ឱ្យមនុស្សគ្រប់រូបទទួលបានឱកាសស្មើគ្នា ដោយមិនគិតពីភេទ អាយុ ពណ៌សម្បុរ ជាតិសាសន៍ ជនជាតិដើមភាគតិច ភាសា សាសនា គំនិត នយោបាយ ដើមកំណើត ឬពិការភាព ជាពិសេសជនងាយរងគ្រោះ។ សេចក្តីប្រកាសនេះបានគូសបញ្ជាក់ថា "គ្មាននរណាម្នាក់ ត្រូវបានទុកចោលឡើយ"។

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើនរួមទាំងជនមានពិការភាពផងដែរ។ ប្រជាជនកម្ពុជាក៏ប្រឈមនឹងការធ្លាក់ទៅក្នុងពិការភាព ដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម។ ក្រៅពីនេះ ពិការភាពផ្សេងទៀតបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើតចាស់ជរា និងមូលហេតុផ្សេងៗទៀត។ តាមរបាយការណ៍ចន្លោះជំរឿនឆ្នាំ២០១៣ របស់ក្រសួងផែនការ ចំនួនជនមានពិការភាពនៅកម្ពុជាមាន ៣០១,៦២៩នាក់ ស្មើនឹង២.០៦% នៃប្រជាជនសរុប ១៤,៦៧៦,៥៩១នាក់ ក្នុងឆ្នាំ២០១៣ ក្នុងនោះបុរសមានពិការភាពមានចំនួន ១៥៧,០០៨នាក់ ស្មើនឹង៥២.០៥% និងស្ត្រីមានពិការភាពចំនួន ១៤៤,៦២២នាក់ ស្មើនឹង៤៧.៩៥%។ កុមារមានពិការភាពអាយុពី០ឆ្នាំដល់១៤ឆ្នាំមានចំនួន ៣២,០៥៦នាក់ ស្មើនឹង១០.៦៣% នៃជនមានពិការភាពសរុប។ ទិន្នន័យនេះអាចធ្វើជាមូលដ្ឋានក្នុងការកំណត់សកម្មភាពជាក់ស្តែង និងការវិនិយោគប្រកបដោយជោគជ័យសម្រាប់ជនមានពិការភាពគ្រប់រូប។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលចតុកោណទី៤ មុំទី៣ អាទិភាពទី៤ ចែងអំពីការបន្តគោលនយោបាយជាតិចំពោះជនមានពិការភាពតាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ ការពង្រឹង

ការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ការជំរុញកិច្ចការពារ និងលើកកម្ពស់សិទ្ធិ និងសុខុមាលភាពជនពិការស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាពឆ្នាំ២០១៤-២០១៨ មានទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន០៩ ផ្តោតលើការកាត់បន្ថយភាពក្រីក្ររបស់ជនមានពិការភាព ការផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមភាព ព្រមទាំងការស្តារលទ្ធភាពសកម្មភាពកាយសម្បទា និងសតិបញ្ញា ការ ផ្តល់សេវាយុត្តិធម៌ ការការពារ ការរើសអើង ការរំលោភបំពាន ការប្រមាថ ការកេងប្រវ័ញ្ចលើជនមានពិការភាព។ ផែនការនេះផ្តោតទៅលើការអប់រំ ការចូលរួមក្នុងការសម្តែងមតិ ការទទួលព័ត៌មាន និងទំនាក់ទំនងចំពោះជនមានពិការភាព ការធានាសមភាពយេនឌ័រ និងការលើកកម្ពស់សមត្ថភាពស្ត្រី និងកុមារមានពិការភាព ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយថ្នាក់អន្តរជាតិផងដែរ។

ពីឆ្នាំ២០០៨-២០១៨ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តគោលនយោបាយស្តីពីការអប់រំកុមារមានពិការភាព ដែលធានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យមានឱកាសស្មើៗគ្នាក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋាន ក្នុង និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់កម្រិតជីវភាព ភេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ។ ជាក់ស្តែង ក្នុងឆ្នាំសិក្សា២០១៧-២០១៨ កុមារ និងយុវជនមានពិការភាព ចំនួន៥៤,៨៣៨នាក់ ស្រី២២,៦២១នាក់បានចូលរៀន។ មាត្រា៧៤ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា "រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ"។ ច្បាប់ស្តីពីការអប់រំត្រង់មាត្រា៣៨ បានចែងថា "រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការអប់រំពិសេស សម្រាប់ជនពិការ និងអ្នកសិក្សាពូកែ ដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់។ ការអប់រំពិសេសផ្តល់ចំពោះអ្នកសិក្សាពូកែឱ្យស្របតាមបញ្ញា និងទេពកោសល្យរបស់អ្នកសិក្សានោះ និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាមានពិការភាពអាចសិក្សាបានដោយសមរម្យ"។ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការត្រង់មាត្រា២៧ រហូតដល់មាត្រា៣២ បានលើកកម្ពស់សិស្ស និស្សិតមានពិការភាពគ្រប់រូបឱ្យមានសិទ្ធិចូលសិក្សា និងទទួលបានការអប់រំ។

ឆ្លើយតបទៅនឹង រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងគោលនយោបាយនានា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្តីពីការអប់រំបរិយាបន្ន។ គោលនយោបាយនេះបានកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន ដើម្បីលើកស្ទួយសិទ្ធិជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។

ផែនការសកម្មភាព និងការប្តេជ្ញាចិត្តដែលធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡាក៏ជាការឆ្លើយតបមួយចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលជាក្របខណ្ឌអភិវឌ្ឍសកលចម្បងសម្រាប់ឆ្នាំ២០១៥-២០៣០។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពបានបញ្ចូលការផ្តោតការយកចិត្តទុកដាក់ដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត។ គោលដៅទាំងនោះ រួមមាន៖

- **គោលដៅទី១** ៖ កាត់បន្ថយភាពក្រីក្រ បង្កើនកិច្ចការ និងជំរុញទស្សនវិស័យការងារ
- **គោលដៅទី២** ៖ លើកកម្ពស់ការចូលរួមក្នុងដំណើរការនយោបាយ និងការសម្រេចចិត្ត
- **គោលដៅទី៣** ៖ កែលម្អឱកាសប្រើប្រាស់បរិស្ថានរូបវន្តមធ្យោបាយដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង
- **គោលដៅទី៤** ៖ ពង្រឹងកិច្ចការពារសង្គម
- **គោលដៅទី៥** ៖ ពង្រីកកិច្ចអន្តរាគមន៍ និងអប់រំបឋម
- **គោលដៅទី៦** ៖ ធានាសមភាពយេនឌ័រ និងការលើកកម្ពស់សមត្ថភាពស្ត្រី
- **គោលដៅទី៧** ៖ ធានាការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដែលមានរួមបញ្ចូលជនមានពិការភាព
- **គោលដៅទី៨** ៖ កែលម្អភាពអាចទុកចិត្តបាន និងភាពអាចប្រៀបធៀបបាននៃទិន្នន័យជនមានពិការភាព

- **គោលដៅទី៩ ៖** ពន្លឿនការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងការធ្វើសុខដុមនីយកម្មនីតិកម្មជាតិជាមួយអនុសញ្ញានេះ
- **គោលដៅទី១០ ៖** ពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរតំបន់។

ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដើម្បីដាក់ចេញនូវសកម្មភាពអនុវត្តជាក់លាក់ សំដៅសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ។

### *១.២. ចក្ខុវិស័យ*

អភិវឌ្ឍជនស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូបឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។

### *១.៣. គោលបំណង*

បណ្តុះការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ពេញលេញ ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។

## ២.គោលដៅ

- ធានាការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងអន្តរាគមន៍ទាន់ពេល
- ផ្តល់សេវាអប់រំមានគុណភាព ប្រកបដោយបរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត
- កសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន
- លើកកម្ពស់ការយល់ដឹង និងការចូលរួម។

## ៣.យុទ្ធសាស្ត្រ

គោលនយោបាយស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨ និងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំឡើងតាមរយៈកិច្ចពិគ្រោះយោបល់ជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍនានា។ កិច្ចពិគ្រោះយោបល់នេះបានជួយកំណត់ពីយុទ្ធសាស្ត្រសំខាន់ៗ ដែលជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពដើម្បីអនុវត្ត។

### *៣.១. វិសាលភាព*

ផែនការសកម្មភាពអប់រំបរិយាបន្ន គ្របដណ្តប់ការផ្តល់សេវាអប់រំសម្រាប់អ្នកសិក្សាមានតម្រូវការពិសេស ចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់កម្រិតឧត្តមសិក្សា តាមរូបភាពអប់រំ ក្នុងប្រព័ន្ធអប់រំ ក្រៅប្រព័ន្ធអប់រំ និងការអប់រំក្រៅផ្លូវការ។

យោងតាមប្រកាសអន្តរក្រសួងឆ្នាំ២០១១ ស្តីពីការចំណែកថ្នាក់ប្រភេទពិការភាពដូចខាងក្រោម៖

- *ពិការកាយសម្បទា*
  - **ពិបាកក្នុងការធ្វើចលនា ៖** ជនទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា(ដោយរាងកាយ) ផ្លាស់ទីដោយលំបាក ឬលំបាកកម្រើកផ្នែកណាមួយនៃរាងកាយ ឬមិនអាចកម្រើកបាន។ ឧទាហរណ៍៖ ដាច់ដៃ ដាច់ជើង ស្វិតដៃ ស្វិតជើង ស្វិតសាច់ដុំ គាំងសន្លាក់ បាក់ឆ្អឹង សាច់ដុំរួញខ្លី ខូចប្រព័ន្ធបញ្ជាចលនារបស់ខួរក្បាល ជើងខ្ទេរ ជើងកែក ទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀងខ្លួន / កំណាត់ខ្លួន / អវៈយវៈ ខូចសរសៃ (Nerve) កំហូចឆ្អឹងខ្នង (កោងទៅមុខ កោងទៅចំហៀង និងកោងទៅក្រោយ) ពិការដោយសារផលវិបាកនៃ ជំងឺ ខូចស្នាម្នាង ភ្លាត់ត្រគាគធ្ងន់ធ្ងរ របួសខួរឆ្អឹងខ្នង គ្រិចធ្ងន់ធ្ងរ រលាកធ្ងន់ធ្ងរ (ភ្លើង ទឹកអាស៊ីត...)។
  - **ពិបាកក្នុងការស្តាប់ ៖** ជនទាំងឡាយណាដែលពិបាកក្នុងការស្តាប់ ឬលទ្ធភាពនៃការស្តាប់ចុះខ្សោយ ឬមិនអាចស្តាប់បាន (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា... ។ល។) ឧទាហរណ៍៖ ថ្លង់ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបៅអំបែកធ្ងន់ធ្ងរ រន្ធត្រចៀកមានដុំពក។

- **ពិបាកក្នុងការនិយាយ ៖** ជនទាំងឡាយណាដែលពិបាកក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្ដាប់ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា...។ល។) ឧទាហរណ៍៖ និយាយគ្រឡាន់ (អណ្ដាតធំ) / ត្រដិតធ្ងន់ធ្ងរ ឆែបក្រអូមមាត់ ក្រឡើតក្រងូវ និយាយមិនច្បាស់ និយាយមិនចេញ គ ផលវិបាកនៃជំងឺ ។
- **ពិបាកក្នុងការមើល ៖** ជនទាំងឡាយណាដែលមានគំហើញចុះខ្សោយ ឬមិនអាចមើលឃើញ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា...។ល។) ឧទាហរណ៍៖ ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតសរសៃបាតភ្នែក ភ្នែកលៀនមើលមិនឃើញ កន្ទុយថ្លែនធ្ងន់ធរ ភ្នែកឡើងបាយ ត្រាក់កូមធ្ងន់ធ្ងរបណ្ដាលមានប្រែងចាក់ ភ្នែកស្រលៀង ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សន្លាកកញ្ចក់ភ្នែក សំពាធទឹកក្នុងភ្នែកកើនឡើង រលាកសរសៃបាតភ្នែក ងងឹតពណ៌។
- **ពិបាកសរីរាង្គខាងក្នុង៖** ជនទាំងឡាយណាដែលវះកាត់សរីរាង្គខាងក្នុង សំខាន់ៗ (ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញ) ឬខ្សោយសរីរាង្គខាងក្នុង ឬចុះខ្សោយមុខងារនៃភាពស៊ាំ និងមានជំងឺរ៉ាំរ៉ៃ...។ល។ ឧទាហរណ៍៖ ខ្សោយមុខងារសរីរាង្គ៖ បេះដូង ក្រលៀន ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន ថ្លើម។

- **ពិការសតិបញ្ញា**

ជនទាំងឡាយណាដែលមានផលវិបាកក្នុងការចងចាំ ភ្លេចច្រើន ឬមិនអាចធ្វើដូចមនុស្សដទៃទៀត ដែលមានអាយុដំណាលគ្នា (ពីកំណើតដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ។ល។) ឧទាហរណ៍៖ បញ្ញាលូតលាស់យឺត រៀនខ្សោយ / ការចងចាំមានកម្រិត (Cretinism) ខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល (Cerebral Palsy) និងជំងឺដោនសាំងដ្រូម មានចរិតទុយមុយ(Autism)

- **ពិការផ្លូវចិត្ត**

ជនទាំងឡាយណាដែលមានវិប្បត្តិផ្នែកអាកប្បកិរិយា អារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ ហើយរំខានដល់ការបំពេញមុខងារប្រចាំថ្ងៃ។ ឧទាហរណ៍៖ អាក្រាត និយាយ សើច យំ ច្រៀង រាំលេង តែម្នាក់ឯងខុសពីប្រក្រតី ស្ងឹងស្ងាត ដើរគេដើរឯង វាយ ឬប្រព្រឹត្តអំពើហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ ជំងឺមន្ទិលសង្ស័យ វិកលចរិត ខូចសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង ។

- **ពិការផ្សេងៗ**

ជនទាំងឡាយណាដែលលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិនអាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ ឬពហុពិការ។ ឧទាហរណ៍៖ មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ តឿ គ្រិន ពកក ផលវិបាកក្នុងការបំពេញមុខងារដោយសារគ្រោះថ្នាក់ និងជំងឺរ៉ាំរ៉ៃ...។ល។

### ៣.២. យុទ្ធសាស្ត្រសំខាន់ៗ

ផែនការសកម្មភាពផ្ដោតលើយុទ្ធសាស្ត្រសំខាន់ៗចំនួន៩ដូចខាងក្រោម៖

១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ
២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ
៣. អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន
៤. ផ្ដល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌
៥. ធានាឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្ដីត្រូវការពិសេស
៦. អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យស្អាត
៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន
៨. លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្ដីពីការអប់រំបរិយាបន្ន
៩. ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

## ៤ .សង្ខេបសកម្មភាពសំខាន់ៗ

| ផ្នែកសំខាន់ៗ | សកម្មភាពសម្រាប់រយៈពេលមធ្យម (២០១៩-២០២១) | សកម្មភាពសម្រាប់រយៈពេលវែង (២០១៩-២០២៣) |
|---|---|---|
| ១. ការបង្កើតយន្តការ និងក្របខណ្ឌគតិយុត្ត | • ធ្វើបច្ចុប្បន្នកម្ម និងពង្រឹងសមត្ថភាពក្រុមការងារអប់រំបរិយាបន្ន និងអ្នកសិក្សាដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់ថ្នាក់ក្រសួង អយកថ្នាក់មន្ទីរអេយក. រាជធានី ខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានសិក្សាសាធារណៈ | • បង្កើត ធ្វើសុពលភាព និងផ្សព្វផ្សាយឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធការអប់រំបរិយាបន្ន និងអ្នកសិក្សាពូកែ ដែលមានទេពកោលសល្យ និង/ឬបញ្ញាខ្ពស់ រៀបចំផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣ |
| ២.ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌ | • ផលិតសៀវភៅសំឡេង (Audio Book) សម្ភារៈ (2D, 3D) សម្រាប់បង្រៀនសិស្សពិការភ្នែក និងកែសម្រួលកញ្ចប់សម្ភារអំណានថ្នាក់ដំបូងជាអក្សរប្រៃយ៍ អក្សរពុម្ពធំសម្រាប់សិស្សពិការភ្នែក និងសិស្សខ្សោយគំហើញ | • បំប៉នវិធីសាស្ត្របង្រៀនដែលមានភាពបត់បែន មានលក្ខណៈជាសិស្សមជ្ឈមណ្ឌលដោយប្រើប្រាស់កញ្ចប់អំណានថ្នាក់ដំបូងសម្រាប់សិស្សពិការភ្នែក គ ថ្លង់<br>• រៀបចំប្រព័ន្ធវាយតម្លៃ មានភាពបត់បែន ដើម្បីឱ្យជនមានតម្រូវការពិសេសអាចចូលរួមប្រឡង និងផ្តល់ការសមម្របសម្រួលសមស្រប<br>• ពង្រឹងថ្នាក់អប់រំពិសេស និងថ្នាក់សមាហរណកម្ម នៅគ្រប់ភូមិសិក្សាដើម្បីផ្តល់ការអប់រំឱ្យសមស្របទៅនឹងអាយុរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស |
| ៣.ការគាំទ្រហិរញ្ញវត្ថុ | • សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលមូលដ្ឋាន វិស័យឯកជន និងសម្បុរសជន ដើម្បីកៀរគរធនធានហិរញ្ញវត្ថុគាំទ្រដល់អ្នកសិក្សាដែលមានតម្រូវការពិសេស<br>• ជានាការវិភាជន៍ថវិការដ្ឋ ក្នុងការគាំទ្រការសិក្សាជនដែលមានតម្រូវការពិសេស | • សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលមូលដ្ឋាន វិស័យឯកជន និងសម្បុរសជន ដើម្បីកៀរគរធនធានហិរញ្ញវត្ថុគាំទ្រដល់អ្នកសិក្សាដែលមានតម្រូវការពិសេស<br>• ជានាការវិភាជន៍ថវិការដ្ឋ ក្នុងការគាំទ្រការសិក្សាជនដែលមានតម្រូវការពិសេស |
| ៤.ការបណ្តុះបណ្តាលធនធានមនុស្ស | • ពង្រឹងគុណវុឌ្ឍគ្រូបង្រៀន ទៅលើជំនាញថ្មី ដូចជាស្ទែម(STEM) សម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស<br>• អភិវឌ្ឍកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូ នៅវិទ្យាស្ថានជាតិអប់រំពិសេស | • អភិវឌ្ឍឯកសារបណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសនៅគ្រប់ភូមិសិក្សា<br>• អភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលសម្រាប់បង្រៀនសិស្សមានពិការភាពដូចជា ពិការភ្នែក គថ្លង់ សតិបញ្ញា...។ល។ |

## ៥ .ផែនការសកម្មភាព

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| *យុទ្ធសាស្ត្រ ៥.១. ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ* | | | | | | | | | | | | | |
| **គោលបំណង ៖** រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការសម្រាប់អនុវត្តគោលនយោបាយ ក្របខណ្ឌច្បាប់ ដែលមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងអ្នកទទួលខុសត្រូវឱ្យមានប្រសិទ្ធភាព។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** ជនស្ថិតក្នុងសេចក្ដីត្រូវការពិសេសទទួលបានសេវាអប់រំ ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត។ | | | | | | | | | | | | | |
| ៥.១.១ រៀបចំលិខិតបទដ្ឋាន និងយន្តការសម្រាប់អនុវត្តគោលនយោបាយស្ដីពីការអប់រំបរិយាបន្ន ឱ្យមានប្រសិទ្ធភាព | ៥.១.១.១ ធ្វើសុពលភាពនិងផ្សព្វផ្សាយឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធការអប់រំបរិយាបន្ន និងអ្នកសិក្សាពូកែ ដែលមាន ទេពកោសល្យ និង/ឬបញ្ញាខ្ពស់ | ចំនួនឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធការអប់រំបរិយាបន្ន និងអ្នកសិក្សាពូកែ ដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់ | ឯកសារគតិយុត្តចំនួន៥៖ មានអនុក្រឹត្យ សារាចរណែនាំ សេចក្ដីណែនាំ ត្រូវបានសម្រេច | X | X | X | X | X | -នា.អប់រំពិសេស | -អាជ្ញាធរ នា.ពាក់ព័ន្ធ<br>-មន្ទីរ រាជធានី ខេត្ត<br>-ការិ.អយក.ក្រុង ស្រុក ខណ្ឌ និងដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូ | $១២,000 | |
| | ៥.១.១.២ រៀបចំផែនការសកម្ម ភាពស្ដីពីការអប់រំ បរិយាបន្នឆ្នាំ ២០១៩-២៣ | ផែនការសកម្មភាពស្ដីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២៣ បានរៀបចំ និងអនុម័ត | ផែនការសកម្មភាពស្ដីពីការអប់រំបរិយាបន្ន ២០១៩-២៣ បានអនុម័ត និងដាក់ឱ្យអនុវត្ត | X | | | | | -នា.អប់រំពិសេស | -នា.ពាក់ព័ន្ធ<br>-មន្ទីរ រាជធានី ខេត្ត<br>-ការិ.អយក.ក្រុង ស្រុក ខណ្ឌ<br>-អាជ្ញាធរ និងដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.១.២ លើកកម្ពស់ និង ពន្លឿនការអនុវត្តន៍គោលនយោបាយ ក្របខណ្ឌច្បាប់ យន្តការពាក់ព័ន្ធ ដែលមានស្រាប់ និង យន្តការថ្មី | ៥.១.២.១ ពង្រឹងការអនុវត្ត ផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន ២០១៩-២០២៣ និង រៀបចំផែនការ អនុវត្ត | ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន | ចំនួន២ដង ក្នុងឆ្នាំ២០១៩៖ ថ្នាក់ក្រសួង និង អ្នកពាក់ព័ន្ធ(១) កម្រិត រាជធានី ខេត្ត/ ក្រុង ស្រុក ខណ្ឌ (១) | X | | | | | -នា.អប់រំពិសេស | -នាយកដ្ឋាន និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១២,៥00 | -នា.អប់រំពិសេស<br>-មន្ទីរអេយក.<br>-ការិ.អេយក. |
| ៥.១.៣ កសាងផែនការសកម្មភាពនានា ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និង ការទទួលខុសត្រូវ | ៥.១.៣.១ កិច្ចប្រជុំរៀបចំផែនការសកម្មភាពជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងការអប់រំបរិយាបន្ន បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង មន្ទីរ រាជធានីខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ សាលារៀន | ផែនការសកម្មភាព ជាអាទិភាព ឆ្លើយតបទៅនឹងការអប់រំបរិយាបន្ន | កិច្ចប្រជុំចំនួន ២លើកដើម្បី បញ្ចូល ផែនការសកម្មភាពអប់រំបរិយាបន្នទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំអាទិភាពទៅនឹងការអប់រំបរិយាបន្ន ក្រសួង(១) រាជធានីខេត្ត(២៥) ក្រុង ស្រុក ខណ្ឌ (១៩៧) | X | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក<br>-ការិ.ក្រុង ស្រុក ខណ្ឌ និងដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូ | $១២,000 | |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាព ទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.១.៤ ផ្សព្វផ្សាយគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ការអនុវត្តន៍គោលនយោបាយ | ៥.១.៤.១ ផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ដល់នាយកដ្ឋានពាក់ព័ន្ធ មន្ទីរ. ការិ.អយក សាលារៀន ដៃគូ និងអ្នកពាក់ព័ន្ធ | ផែនការសកម្មភាពអប់រំបរិយាបន្ន | ថ្នាក់ជាតិ ថ្នាក់មន្ទីរ រាជធានី ខេត្ត និងការិ. អយក ក្រុង ស្រុកខណ្ឌ | X | | | | | -នា.អប់រំពិសេស | -ក្រ.សង្គមកិច្ច<br>-ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍<br>-នា.ពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១៥,000 | -នា.អប់រំពិសេស<br>-នា.គោលនយោបាយ |
| ***យុទ្ធសាស្ត្រ ៥.២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ*** | | | | | | | | | | | | | |
| **គោលបំណង ៖** សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់អត្តសញ្ញាណបឋម ជាមួយភាគីពាក់ព័ន្ធ ដើម្បីវាយតម្លៃ ផ្តល់ឧបករណ៍ជំនួយ ផ្តល់សេវាស្តារលទ្ធភាព និងធ្វើអន្តរាគមន៍ទាន់ពេល ដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** ជនដែលស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបានសេវាស្តារលទ្ធភាព ដើម្បីធានាបានការចូលរៀន។ | | | | | | | | | | | | | |
| ៥.២.១ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការ កំណត់អត្តសញ្ញាណបឋម ដោយប្រើ ប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណ | ៥.២.១.១ រៀបចំឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណពិការភាព | ឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណពិការភាព | ឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណពិការភាព | X | | | | | -នា.អប់រំពិសេស | -មន្ទីរសុខាភិបាល<br>-រដ្ឋអំណាចមូលដ្ឋាន<br>-មន្ទីរសង្គមកិច្ច | -ថវិកាកម្មវិធី<br>-ដៃគូ | $២0,000 | |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាព ទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.២.២ សហការជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ ដើម្បីវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេលដល់ជនស្ថិតនៅក្នុងសេចក្តីត្រូវការពិសេស | ៥.២.១.២ រៀបចំឧបករណ៍ សម្រាប់ធ្វើលក្ខណៈវិនិច្ឆ័យ អ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់ | ចំនួនឧបករណ៍សម្រាប់ធ្វើលក្ខណៈវិនិច្ឆ័យអ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់ | ឧបករណ៍ចំនួន ៣ភូមិសិក្សា | X | X | X | X | X | -នា.អប់រំពិសេស | -នា.ធានាគុណភាព<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-នា.បណ្តុះបណ្តាល<br>-នា.បឋម<br>-នា.មធ្យម<br>-នា.ពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១២,000 | -នា.អពស<br>-នា.ធាគុណភាព<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-នា.បណ្តុះបណ្តាល<br>-នា.បឋម មធ្យម<br>-នា.ពាក់ព័ន្ធ |
| | ៥.២.១.៣ បំប៉នសមត្ថភាពគ្រូ អាជ្ញាធរ និង សហគមន៍ពីការប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណពិការភាព | ចំនួនសាលារៀនដែលប្រើប្រាស់ឧបករណ៍ | ៥០ សាលា (មត្តេយ្យ បឋម មធ្យម) បានប្រើប្រាស់ឧបករណ៍ | | | X | X | X | -នា.អប់រំពិសេស | -ក្រសួងសុខាភិបាល<br>-អាជ្ញាធរមូលដ្ឋាន និងក្រសួងសង្គមកិច្ច | -ថវិកាកម្មវិធី<br>-ដៃគូ | $៣0,000 | -នា.អប់រំពិសេស<br>-ក្រ.សង្គមកិច្ច |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) ១ | ២ | ៣ | ៤ | ៥ | អង្គភាព ទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.២.១.៤ បំប៉នសមត្ថភាពក្រុមការងារមន្ទីរអេយក ការិ.អេយកស្រុក គ្រូ អាជ្ញាធរ និងសហគមន៍ពីការប្រើប្រាស់ឧបករណ៍កំណត់លក្ខណៈវិនិច្ឆ័យអ្នកសិក្សាពូកែ ដែលមានទេព្យកោសល្យ និង/ឬបញ្ញាខ្ពស់ | ចំនួនខេត្ត ស្រុក គ្រូ អាជ្ញាធរ និងសហគមន៍ ដែលប្រើប្រាស់ឧបករណ៍ | ៦ខេត្ត ៣០ស្រុក ១៥០គ្រូ អាជ្ញាធរ ៣០ និងសហគមន៍៣០ ដែលប្រើប្រាស់ឧបករណ៍ | | X | X | X | X | -នា.អប់រំពិសេស | -នា.ធានាគុណភាព<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-នា.បណ្តុះបណ្តាល<br>-នា.បឋម<br>-នា.មធ្យម<br>-នា.ពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៦០,000 | -នា.អប់រំពិសេស<br>-នា.ពាក់ព័ន្ធ<br>-មន្ទីរអេយក.<br>-ការិ.អេយក |
| ៥.២.២ សហការជាមួយស្ថាប័ន ភាគីពាក់ព័ន្ធដើម្បីវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេលដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.២.២.១ ធ្វើបច្ចុប្បន្នកម្មទិន្នន័យ ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស នៅមន្ទីរអេយក. ការិ.អេយក និងសាលារៀន | បញ្ជីឈ្មោះជនស្ថិតក្នុងសេចក្តីត្រូវការពិសេស នៅមន្ទីរអេយក ការិ.អេយក និងសាលារៀន | ធ្វើសុពលភាពបញ្ជីឈ្មោះ ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ទាំង២៥ រាជធានីខេត្ត | X | X | X | X | X | -នា.អប់រំពិសេស | -ភ្នាក់ងារសង្គមកិច្ច<br>-ក្រសួងសុខាភិបាល អាជ្ញាធរមូលដ្ឋាន និងមាតាបិតាសិស្ស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,000 | -នា.អប់រំពិសេស<br>-នា.EMIS |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.២.៣ កំណត់អត្តសញ្ញាណ វិភាគទិន្នន័យពិការភាព ផ្តល់ឧបករណ៍ជំនួយ និងផ្តល់សេវាស្តារលទ្ធភាពដើម្បីធានាបានការចូលរៀន | ៥.២.៣.១ សហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីវាយតម្លៃតម្រូវការតាមប្រភេទពិការភាព អន្តរាគមន៍ទាន់ពេល | ចំនួនជនមានពិការភាពដែលទទួលបានការវាយតម្លៃពីតម្រូវការជាក់លាក់ | ចំនួនសិស្សពិការប្រហែល ១.៥០%ក្នុង៥០សាលាទទួលបានសេវា | | | | X | X | -នា.អប់រំពិសេស | -នាយកដ្ឋាន<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៦០,000 | -នា.អប់រំពិសេស<br>-នា.ពាក់ព័ន្ធ<br>-ដៃគូពាក់ព័ន្ធ<br>-ក្រ.សង្គមកិច្ច<br>-ក្រ.សុខាភិបាល |
| | ៥.២.៣.២ ផ្តល់ឧបករណ៍ជំនួយ និងសេវាគាំទ្រផ្សេងៗដល់ជនមានពិការភាព | ចំនួនជនមានពិការភាពបានទទួលឧបករណ៍ជំនួយនិងសេវាផ្សេងៗ | ចំនួនសិស្សពិការប្រហែល ១.៥០%ក្នុង៥០សាលាទទួលបានឧបករណ៍ជំនួយ | | | | X | X | -នា.អប់រំពិសេស | -ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៦០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |

*យុទ្ធសាស្ត្រ ៥ .៣. អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន*

**គោលបំណង ៖** ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំស្តីពីជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទៅក្នុងប្រព័ន្ធព័ត៌មានអប់រំ ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុង និងក្រៅសាលា ដើម្បីទទួលបានការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ផលសម្រេច ៖** ទទួលបានទិន្នន័យព័ត៌មានស្តីពីជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ឆ្លើយតបទៅនឹងបច្ចុប្បន្នភាព។

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៣.១ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដើម្បីបញ្ចូលព័ត៌មានអំពីតម្រូវការអប់រំពិសេសទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ៥.៣.១.១ សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកែសម្រួលសូចនាករ ឆ្លុះបញ្ចាំងពីពិការភាពក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ដោយបន្សីជាមួយកម្រងសំណួរ (Washington Group on disability and education module) | បញ្ជីឈ្មោះសូចនាករ ដែលពាក់ព័ន្ធជាមួយជនដែលមានពិការភាពក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) | កម្រងសំណួរ (Washington Group on disability and education module) | | X | X | X | X | -នា.អប់រំពិសេស<br>-នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | -នា.គ្រប់គ្រងព័ត៌មានអប់រំ<br>-នា.អប់រំកុមារតូច<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>-នា.សុខភាពសិក្សា និងដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូ | $១០០,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអយក.<br>-ការិ.អយក.<br>-អ្នកពាក់ព័ន្ធ |
| | ៥.៣.១.២ កំណែទម្រង់ប្រព័ន្ធទិន្នន័យគ្រប់គ្រងព័ត៌មានអប់រំ ដើម្បីបញ្ចូលទិន្នន័យកុមារពិការក្នុងសាលា | ប្រព័ន្ធទិន្នន័យគ្រប់គ្រងព័ត៌មានអប់រំត្រូវបានកែសម្រួល | ប្រព័ន្ធទិន្នន័យគ្រប់គ្រងព័ត៌មានអប់រំត្រូវបានកែសម្រួល | | | x | | | -នា.គ្រប់គ្រងព័ត៌មានអប់រំ<br>-នា.អប់រំពិសេស | -អគ្គនាយដ្ឋានគោលនយោបាយ និងផែនការ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣០.០០០ | -នា.គ្រប់គ្រងព័ត៌មានអប់រំ<br>-នា.អប់រំពិសេស |
| | ៥.៣.១.៣ បំប៉នសមត្ថភាពគ្រូ អាជ្ញាធរ និង សហគមន៍ពីការប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណជនមានពិការភាពក្នុងសាលា | ចំនួន២៥ រាជធានី ខេត្តទទួលការបំប៉នប្រើប្រាស់ឧបករណ៍ | ចំនួនសាលារៀនទាំង២៥ រាជធានីខេត្តបានប្រើប្រាស់ឧបករណ៍ | | X | | | | -នា.អប់រំពិសេស<br>-នា.EMIS | -ក្រសួងសុខាភិបាល<br>-រដ្ឋអំណាចមូលដ្ឋាន<br>-ក្រសួងសង្គមកិច្ច | -ថវិកាកម្មវិធី<br>-ដៃគូ | $ ១៥០,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអយ<br>.-ការិ.អយក<br>-អ្នកពាក់ព័ន្ធនានា |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៣.១.៤ ប្រមូល និងបញ្ចូលស្ថិតិ ជនមានពិការភាពក្រៅសាលា ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ | ស្ថិតិជនមានពិការភាពនៅក្រៅសាលា | លទ្ធផលស្ថិតិជនមានពិការភាពក្រៅសាលា | | x | | | | -នា.អប់រំពិសេស<br>-នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំEMIS | -នា.អប់រំពិសេស<br>-នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | -ថវិកាកម្មវិធី<br>-ដៃគូ | $ ១០,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអេយ<br>.-ការិ.អេយក<br>-អ្នកពាក់ព័ន្ធនានា |
| ៥.៣.២ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ចូលទិន្នន័យជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥.៣.២.១ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីប្រមូលស្ថិតិជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ | ស្ថិតិជាក់លាក់ដាក់បញ្ចូលក្នុង EMIS អំពីជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ | ចំនួនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសដែលកំពុងទទួលការបណ្តុះបណ្តាល | | X | | | | -នា.អប់រំពិសេស<br>-នា.EMIS | -ក្រសួងសង្គមកិច្ច<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា ជីវៈ និងដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |

| យុទ្ធសាស្ត្រវេង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៣.៣ សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបញ្ចូលទិន្នន័យជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុង និងក្រៅសាលា | ៥.៣.៣.១ ក្រសួងអយក សហការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនិតិសម្បទា ក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធ ដើម្បីប្រមូលស្ថិតិជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ទាំងក្នុងសាលារៀន និងនៅក្នុងសហគមន៍ | ស្ថិតិជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុងសាលារៀន និងនៅក្នុងសហគមន៍ត្រូវបានកំណត់ | ចំនួនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុង និងក្រៅសាលា | | X | | | | -នា.អប់រំពិសេស | -ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល<br>-ក្រុមប្រឹក្សាសកម្មភាពជនពិការ និងអាជ្ញាធរដែនដី | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,000 | -ក្រ.សង្គមកិច្ច ក្រុម<br>-ប្រឹក្សាសកម្មភាពជនពិការ និងអាជ្ញាធរ |
| ៥.៣.៤ វិភាគទិន្នន័យឱ្យបានទៀងទាត់ ដើម្បីកំណត់ពីបញ្ហាប្រឈមក្នុងការសិក្សា និងកង្វះខាតធនធាន ដែលត្រូវការសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៣.៤.១ បង្កើតឧបករណ៍ពិនិត្យតាមដានការសិក្សា ស្តីពីតម្រូវការ និងបញ្ហាប្រឈមក្នុងការសិក្សាជនស្ថិតក្នុងសេចក្តីត្រូវការពិសេស រៀងរាល់ ១ឆ្នាំ ២ដង។ | ចំនួន ១ខេត្ត ១ស្រុក ១៥សាលាប្រើប្រាស់ឧបករណ៍ពិនិត្យតាមដានការសិក្សាអនុវត្តសាកល្បងឆ្នាំ២០២០ ហើយអនុវត្តនៅតាមគ្រឹះស្ថានសិក្សាសាធារណៈទូទាំងប្រទេស ចាប់ពីឆ្នាំ២០២១ | ចំនួនសាលាទទួលបានឧបករណ៍តាមដានការសិក្សាយកទៅអនុវត្ត | | X | X | | | -នា.អប់រំពិសេស | -នា.គ្រប់គ្រងព័ត៌មានអប់រំ<br>-នា.អប់រំកុមារតូច<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>-នា.សុខភាពសិក្សា | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,000 | -នា.EMIS<br>-នា.អប់រំពិសេស |

| យុទ្ធសាស្ត្រង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៣.៥ ធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃអ្នកផ្តល់សេវាលើការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងការស្តារនីតិសម្បទា | ៥.៣.៥.១ សហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធ ធ្វើសុពលភាពបញ្ជីឈ្មោះស្ថាប័នដែលផ្តល់អន្តរាគមន៍ និងសេវា សម្រាប់ជនមានពិការភាព | បញ្ជីឈ្មោះស្ថាប័នដែលផ្តល់អន្តរាគមន៍ និងសេវា សម្រាប់ជនមានពិការភាពរៀងរាល់ ១ឆ្នាំ ១ដង | ចំនួនស្ថាប័នដែលផ្តល់អន្តរាគមន៍ និងសេវា សម្រាប់ជនមានពិការភាព | X | X | X | X | X | នា. អប់រំពិសេស | -នា.គ្រប់គ្រងព័ត៌មានអប់រំ<br>-នា.អប់រំកុមារតូច<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>-នា.សុខភាពសិក្សា<br>-ក្រុមប្រឹក្សាសម្មភាពជនពិការ<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល | -ថវិកាកម្មវិធី<br>-ដៃគូ | $៤០,000 | -នា.អប់រំពិសេស<br>-មន្ទីរ.អយក.រាជធានី ខេត្ត<br>-ការិ.អយក.ក្រុង.ស្រុក ខណ្ឌ |

*យុទ្ធសាស្ត្រ ៥.៤. ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌*

**គោលបំណង** ៖ ផ្តល់ការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ឱ្យមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌។

**ផលសម្រេច** ៖ ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបានចំណេះដឹង ទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៤.១ ធានាផ្តល់សេវាចុះឈ្មោះចូលរៀន និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាមានពិការភាពអាចសិក្សាបានសមរម្យ | ៥.៤.១.១ ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីសិទ្ធិទទួលបានសេវាអប់រំពិការភាពដល់សហគមន៍ មាតាបិតាសិស្ស ដើម្បីប្រមូលកុមារមានពិការភាព ឱ្យចុះឈ្មោះចូលរៀន | យុទ្ធនាការផ្សព្វផ្សាយ អំពីសិទ្ធិកុមារមានពិការភាព ឱ្យចុះឈ្មោះ ចូលរៀន | សាលារៀនទូទាំងប្រទេសបើកយុទ្ធនាការមួយឆ្នាំម្តង | | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក.រាជធានីខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣0,000 | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>- អាជ្ញាធរ និងដៃគូពាក់ព័ន្ធ |
| | ៥.៤.១.២ គាំទ្រការរៀបចំសាលារៀន និងផ្តល់ហេដ្ឋារចនាសម្ពន្ធរូបវន្ត សមស្របដល់អ្នកសិក្សាមានពិការភាព | ចំនួនសាលារៀនអប់រំបរិយាបន្ន | ចំនួនសាលាក្នុងឆ្នាំ<br>២០២០=៥<br>២០២១=១០<br>២០២២=១០<br>២០២៣=១០ | | X | X | X | X | -នា.អប់រំពិសេស | -នា.អប់រំកុមារតូច<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>-មន្ទីរអេយក.រាជធានីខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥២៥.000 | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក<br>-អាជ្ញាធរ និងដៃគូពាក់ព័ន្ធ |
| | ៥.៤.១.៣ ផ្តល់ការគាំទ្រដល់សិស្សមានពិការភាព ដើម្បីធានាថា អ្នកសិក្សាទាំងនេះទទួលបានការអប់រំ ប្រកបដោយសមធម៌ និងគុណភាព (កន្លែង ស្នាក់នៅ អាហារហូបចុក មធ្យោបាយដឹកជញ្ជូន... | ចំនួនអ្នកសិក្សាមានពិការភាព ទទួលបានការអប់រំ នៅវិទ្យាល័យអប់រំពិសេស | សិស្ស១នាក់ទទួលបានថវិកា៥០០ដុល្លារក្នុងមួយឆ្នាំ<br>២០១៩=៧០២<br>២០២០=៧០៧<br>២០២១=៧១២<br>២០២២=៧១៩<br>២០២៣=៧២៣ | X | X | X | X | X | -នា.អប់រំពិសេស | -នា. ពាក់ព័ន្ធ មន្ទីរអេយក.រាជធានីខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ<br>-នាយក វិទ្យាល័យអប់រំពិសេស | -ថវិកាកម្មវិធី<br>-ដៃគូ | $១.៧៨០.០០០ | -នា.អប់រំពិសេស<br>-មន្ទីរ.អេយក<br>-វិ.អពស |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៤.១.៤ ផ្តល់ការគាំទ្រដល់អ្នកសិក្សាមានពិការភាព ដើម្បីធានាថា កុមារទាំងនេះទទួលបានការអប់រំប្រកបដោយសមធម៌ និងគុណភាព (កន្លែងស្នាក់នៅ ផ្តល់អ្នកបកប្រែភាសាសញ្ញាទៅតាមសិស្សនៅមហាវិទ្យាល័យ អាហារហូបចុក មធ្យោបាយដឹកជញ្ជូនការគាំទ្រសុខភាព សម្លៀកបំពាក់ សម្ភារសិក្សា និងឧបករណ៍ជំនួយ) | ចំនួនអ្នកសិក្សាមានពិការភាពទទួលបានការអប់រំ នៅវិទ្យាល័យអប់រំពិសេស និងនៅថ្នាក់អប់រំពិសេសដទៃទៀត រួមទាំងថ្នាក់បរិយាបន្ននៅមហាវិទ្យាល័យ | ចំនួនអ្នកសិក្សាមានពិការភាពរៀនមហាវិទ្យាល័យ និងចំនួនសិស្សពិការសតិបញ្ញា | X | X | X | X | X | -នា.អប់រំពិសេស | -នា. ពាក់ព័ន្ធ មន្ទីរអេយក.រាជធានីខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ<br>-នាយក វិទ្យាល័យអប់រំពិសេស មហាវិទ្យាល័យពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $២៤១,៦០០ | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៤.២ ធានាថាកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលឆ្លើយតបទៅនឹងតម្រូវការផ្សេងគ្នារបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៤.២.១ រៀបចំ ក្រុមការងារបច្ចេកទេសតាមជំនាញប្រភេទពិការភាព | ចំនួនក្រុម ជំនាញតាមប្រភេទពិការភាព | ចំនួន៣ ប្រភេទពិការ(ពិការភ្នែក គថ្លង់ ពិការសតិបញ្ញា) | X | X | X | X | X | -នា.អប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិទ្យាល័យអប់រំពិសេសនិងអង្គការដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |
| | ៥.៤.២.២ កែសម្រួលកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាអក្សរស្ទាប និងសៀវភៅភាសាសញ្ញា (អក្សរស្ទាប) សម្រាប់បង្រៀនកុមារពិការភ្នែកគ្រប់កម្រិតថ្នាក់ និងនិយាមសិស្ស គ្រូកំណត់តាមតម្រូវការជាក់ស្តែងរបស់សិស្ស | ចំនួនវិទ្យាល័យអប់រំពិសេសទទួលបានកម្មវិធីសិក្សា សៀវភៅអក្សរស្ទាបនិងសៀវភៅភាសាសញ្ញា | ចំនួនកម្មវិធីសិក្សាពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២<br>២. សៀវភៅសិក្សាជាអក្សរស្ទាប និងសៀវភៅសិក្សាជាភាសាសញ្ញាពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២ | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពសទាំង៥ | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-វិទ្យាល័យអប់រំពិសេសនិងអង្គការដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $៤៣៧,៥០០ | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ |

| យុទ្ធសាស្ត្រង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្ដល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៤.២.៣ បំប៉នគ្រូអំពីការប្រើប្រាស់កម្មវិធីសិក្សាតាមជំនាញ (ពិការភ្នែក គ ថ្លង់ ពិការសតិបញ្ញា) | ចំនួនគ្រូជំនាញតាមប្រភេទពិការភាព | ចំនួនគ្រូដែលទទួលបានការបំប៉ន<br>២០១៩=350នាក់<br>២០២០=255នាក់<br>២០២១=261នាក់<br>២០២២=221នាក់<br>២០២៣=226នាក់ | X | X | X | X | X | នា.អប់រំពិសេស វិទ្យាស្ថានជាតិអប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-វិទ្យាល័យអប់រំពិសេស និងអង្គការដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០០,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអយក.<br>-ការិ.អយក. |
| ៥.៤.៣ ធានាឱ្យមានកម្មវិធីសិក្សាអប់រំពិសេសស្របតាមកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលសម្រាប់ប្រើប្រាស់នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន | ៥.៤.៣.១ បោះពុម្ព និងផ្ដល់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលភាសាសញ្ញា និងអក្សរស្ទាប សម្រាប់ប្រើប្រាស់នៅ សាលាអប់រំបរិយាបន្នវិទ្យាល័យអប់រំពិសេស ថ្នាក់សមាហរណកម្ម និង គ្រឹះស្ថានសិក្សាសាធារណៈ | ចំនួនសៀវភៅសិក្សាគោល ផ្ដល់ជូនសាលាសម្រាប់ប្រើប្រាស់ | ចំនួនសៀវភៅសិក្សាគោល និងកម្មវិធីសិក្សា<br>ឆ្នាំទី១=៥០០០ ក្បាល<br>ឆ្នាំទី២=៣៧៥០ ក្បាល<br>ឆ្នាំទី៣=៣៧៥០ ក្បាល<br>ឆ្នាំទី៤=៣៧៥០ ក្បាល<br>ឆ្នាំទី៥=៣៧៥០ ក្បាល | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា. អភិវឌ្ឍន៍កម្មវិធីសិក្សា | -ថវិកាកម្មវិធី<br>-ដៃគូ | $៣០០,០០០ | |

| យុទ្ធសាស្ត្រង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) ១ | ២ | ៣ | ៤ | ៥ | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥.៤.៤ អភិវឌ្ឍកម្មវិធីសិក្សាអប់រំបរិយាបន្ន សម្រាប់សិស្សមានពិការភាពសតិបញ្ញា | ៥.៤.៤.១ រៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សា សម្រាប់បង្រៀនសិស្សមានពិការភាពសតិបញ្ញា អូទីសឹម | ១. រៀបចំកម្មវិធីសិក្សា<br>២. រៀបចំសៀវភៅសិក្សា | ១. កម្មវិធីសិក្សា និងសៀវភៅសិក្សារៀបចំពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ | | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា. អភិវឌ្ឍកម្មវិធីសិក្សានិងដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $១៥០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |
| ៥.៤.៥ ណែនាំវិធីសាស្ត្របង្រៀនដែលមានភាពបត់បែនទៅក្នុងកម្មវិធីសិក្សាជាតិដែលមានលក្ខណៈជាសិស្សមជ្ឈមណ្ឌល មានការចូលរួម និងសមស្របទៅនឹងវប្បធម៌ | ៥.៤.៥.១ បំប៉នវិធីសាស្ត្របង្រៀនដែលមានភាព បត់បែនមានលក្ខណៈជាសិស្សមជ្ឈមណ្ឌលដោយប្រើប្រាស់កញ្ចប់អំណានថ្នាក់ដំបូងសម្រាប់សិស្សពិការភ្នែក គថ្លង់ | ចំនួនវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម | វិទ្យាល័យអប់រំពិសេសចំនួន៥ និងថ្នាក់សមាហរណកម្ម | | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -នា. អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អភិវឌ្ឍ កម្មវិធីសិក្សា |
| | ៥.៤.៥.២ បំប៉នកម្មវិធីស្ទែម (STEM) សម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស | ចំនួនគ្រូបង្រៀនវិទ្យាល័យអប់រំពិសេសទទួលបានវគ្គបំប៉នកម្មវិធីស្ទែម (STEM) | គ្រូវិទ្យាល័យអប់រំពិសេស ចំនួន ២០នាក់ | | | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.ធានាគុណភាព និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣០,000 | - នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៤.៦ ផ្តល់សម្ភារបង្រៀន និងរៀនឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបស់អ្នកមានតម្រូវការអប់រំពិសេស | ៥.៤.៦.១ ផលិតសៀវភៅសំឡេង (Audio Book) សម្ភារ (2D,3D) សម្រាប់បង្រៀនសិស្សពិការភ្នែក និងកែសម្រួលកញ្ចប់សម្ភារអំណានថ្នាក់ដំបូងជា អក្សរស្ទាប អក្សរពុម្ពធំ សម្រាប់សិស្សពិការភ្នែក និងសិស្សខ្សោយគំហើញ | ចំនួនវិទ្យាល័យអប់រំពិសេស ប្រើប្រាស់សៀវភៅសំឡេង (Audio Book) សម្ភារៈ (2D, 3D) អក្សរស្ទាប អក្សរពុម្ពធំ | វិទ្យាល័យអប់រំពិសេសចំនួន៥ ប្រើប្រាស់ | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១៨០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |
| | ៥.៤.៦.២ សហការជាមួយដៃគូដើម្បីផលិត និងផ្សព្វផ្សាយវីដេអូអំពីការរៀនភាសាសញ្ញាមូលដ្ឋាន និងវីដេអូរឿងដែលមាននៅក្នុងកញ្ចប់អំណានថ្នាក់ដំបូងជាភាសាសញ្ញាសម្រាប់បញ្ចូលក្នុងគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា | ចំនួនមេរៀនផ្សព្វផ្សាយជាវីដេអូនៅក្នុងគេហទំព័រ របស់ក្រសួងអប់រំ យុវជន និងកីឡា | ចំនួន២១ មេរៀននៅឆ្នាំ ២០១៩ និង៣២ មេរៀនទៀតនៅឆ្នាំ២០២៣ | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៤.៧ រៀបចំផែនការអប់រំជាបុគ្គល សម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូប ដោយកំណត់អំពីតម្រូវការសិក្សា | ៥.៤.៧.១ សហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំផែនការអប់រំជាបុគ្គល និងប្រជុំគ្រូតាមសាលាអប់រំបរិយាបន្ន | គ្រូដែលបានប្រជុំធ្វើផែនការជាបុគ្គលតាមសាលាអប់រំបរិយាបន្ន | ចំនួនគ្រូដែលបាន ធ្វើផែនការជាបុគ្គលតាមសាលាអប់រំបរិយាបន្ន | X | X | X | X | X | -នា.អប់រំពិសេស | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-មន្ទីរ.អយក |
| ៥.៤.៨ ជំរុញការគាំទ្រលើសកម្មភាពសិក្សាស្រាវជ្រាវរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៤.៨.១ សហការជាមួយដៃគូ ដើម្បីរៀបចំរចនាសម្ពន្ធ និងសម្ភារបរិក្ខារនៅវិទ្យាស្ថានជាតិអប់រំពិសេស មហាវិទ្យាល័យ ដេប៉ាតេម៉ង់ស្រាវជ្រាវ មណ្ឌលធនធាន និងវិទ្យាល័យអប់រំពិសេស ដើម្បីគរុសិស្ស និស្សិត និងសិស្សមានពិការភាពចូលសិក្សាស្រាវជ្រាវ | ចំនួនដេប៉ាតេម៉ង់ស្រាវជ្រាវ វិទ្យាស្ថានជាតិអប់រំពិសេស មហាវិទ្យាល័យ និងមណ្ឌលធនធាន | ចំនួនដេប៉ាតេម៉ង់ស្រាវជ្រាវចំនួន២ វិទ្យាស្ថានជាតិអប់រំពិសេស មហាវិទ្យាល័យ និងមណ្ឌលធនធានចំនួន៥ | | | | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពសទាំង៥ | -មណ្ឌលធនធានតាមវិទ្យាល័យអប់រំពិសេស<br>-មហាវិទ្យាល័យ<br>-វិទ្យាស្ថានជាតិគរុកោសល្យ<br>-វិទ្យាស្ថានបច្ចេកវិទ្យា<br>-វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៤.៨.២ សហការជាមួយដៃគូ ដើម្បីបំប៉នសមត្ថភាពជំនាញក្នុងការប្រើប្រាស់សម្ភាររូបវន្តដល់អ្នកទទួលបន្ទុកនៅវិទ្យាស្ថានជាតិអប់រំពិសេសមហាវិទ្យាល័យអក្សរសាស្ត្រ ដេប៉ាតេម៉ង់ស្រាវជ្រាវភាសាសញ្ញា អក្សរប្រេយ៍ មណ្ឌលធនធាននៅវិទ្យាល័យអប់រំពិសេស | ចំនួនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបន្ទុក ស្រាវជាវទទួលបានការបំប៉ន សមត្ថភាពជំនាញ | ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបន្ទុក ស្រាវជាវទទួលបានការបំប៉នសមត្ថភាពជំនាញចំនួន ១០នាក់ | | | | X | X | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អប់រំពិសេស | -មណ្ឌលធនធានតាម<br>-វិទ្យាល័យអប់រំពិសេស<br>-មហាវិទ្យាល័យ<br>-វិទ្យាស្ថានជាតិគរុកោល្យ<br>-វិទ្យាស្ថានបច្ចេកវិទ្យា<br>-វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |
| ៥.៤.៩ រៀបចំប្រព័ន្ធវាយតម្លៃមួយដែលមានភាពយុត្តិធម៌ និងភាពបត់បែន ដើម្បីឱ្យជនស្ថិតក្នុង សេចក្តីត្រូវការពិសេសអាចចូលរួមប្រឡងបាន និងផ្តល់ទីកន្លែងប្រឡងសមរម្យ | ៥.៤.៩.១ កែសម្រួលតេស្តវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិ និងតេស្តស្តង់ដាឱ្យស្របតាមប្រភេទពិការភាព | ចំនួនឧបករណ៍តេស្តវាយតម្លៃដោយភាពយុត្តិធម៌ និងបត់បែន | ចំនួនពីរ(គ ថ្លង់ និងពិការភ្នែក) | | X | X | X | X | -នា.អប់រំពិសេស<br>វ.អពស | -នា.អភិវឌ្ឍកម្មវិធី<br>-នា.បណ្តុះបណ្តាល<br>-នា.ធានាគុណភាពអប់រំ -នា.បឋម<br>-នា.កុមារតូច<br>-នា.មធ្យម<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣0,000 | -នា.អប់រំពិសេស<br>-នា.អភិវឌ្ឍកម្មវិធី<br>-នា.បណ្តុះបណ្តាល<br>-នា.ធានាគុណភាពអប់រំ |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៤.៩.២ រៀបចំប្រព័ន្ធវាយតម្លៃ មានភាព បត់បែនដើម្បីឱ្យអ្នកសិក្សាពូកែ ដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់ អាចចូលប្រឡង និងផ្តល់ទីកន្លែងបានសមរម្យ | ឧបករណ៍តេស្តវាយតម្លៃដោយភាពយុត្តិធម៌ | តេស្តវាយតម្លៃត្រូវបានបង្កើត | X | X | X | X | X | -នា.អប់រំពិសេស វិ.អពស | -នា.អភិវឌ្ឍកម្មវិធី<br>-នា.បណ្តុះបណ្តាល<br>-នា.ធានាគុណភាពអប់រំ -នា.បឋម<br>-នា.កុមារតូច<br>-នា.មធ្យម<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៤0,000 | |
| ៥.៤.១០ បង្កើតថ្នាក់សមាហរណកម្មនៅគ្រប់កម្រិតសិក្សា ដើម្បីផ្តល់ការអប់រំឱ្យសមស្របនឹងអាយុរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៤.១០.១ ពង្រឹងថ្នាក់សមាហរណកម្មនៅគ្រប់ភូមិសិក្សា ដើម្បីផ្តល់ការអប់រំឱ្យសមស្របទៅនឹងអាយុរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ចំនួនថ្នាក់សមាហរណកម្មនៅគ្រប់កម្រិតសិក្សា | ចំនួន៩ថ្នាក់សមាហរណកម្ម | | X | X | X | X | -នា.អប់រំពិសេស | -នា.បុគ្គលិក<br>-នា.នីតិកម្ម<br>-នា.បណ្តុះបណ្តាល<br>-នា.ហិរញ្ញវត្ថុ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | -នា.អប់រំពិសេស<br>-មន្ទីរ.អយក |
| ៥.៤.១១ បង្កើតកម្មវិធីគាំពារសង្គម ដើម្បីផ្តល់ការឧបត្ថម្ភគាំទ្រដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៤.១១.១បង្កើតគណៈកម្មការមូលនិធិសមធម៌សង្គម កំណត់ដោយប្រកាសក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតហិបសង្គ្រោះសម្រាប់ជនមានពិការភាព | ចំនួនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន | ចំនួនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ទាំង ២៥ រាជធានីខេត្ត | | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអយក.<br>-ការិ.អយក<br>-នាយកសាលា<br>- សហគមន៍<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌ ពេលវេលា (ឆ្នាំ) | | | | | អង្គភាព ទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៤.១១.២ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ បញ្ចូលតម្រូវការ ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ឃុំ សង្កាត់ដាក់បញ្ចូលផែនការអភិវឌ្ឍន៍ | ឃុំ សង្កាត់ដាក់បញ្ចូលផែនការអភិវឌ្ឍន៍ | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងមហាផ្ទៃ<br>-មន្ទីរអេយក.<br>-ការិ.អេយក<br>-នាយកសាលា<br>- អាជ្ញាធរមូលដ្ឋាន សហគមន៍<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |
| ៥.៤.១២ ធ្វើសមាហរណកម្មសិស្ស និស្សិតស្ថិតក្នុងសេចក្តីត្រូវការពិសេសទៅក្នុងថ្នាក់រៀនចម្រុះតាមដែលអាចធ្វើទៅបាន | ៥.៤.១២.១ ជ្រើសរើស និងបំប៉នអ្នកសម្របសម្រួល និងអ្នកបកប្រែភាសាសញ្ញាសម្រាប់សិស្ស និស្សិតស្ថិតក្នុងសេចក្តីត្រូវការពិសេសដែលរៀនក្នុងថ្នាក់អប់រំបរិយាបន្ន រួចបញ្ជូនបន្តទៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឬមហាវិទ្យាល័យ | -ចំនួនអ្នកសម្របសម្រួល និងអ្នកបកប្រែភាសាសញ្ញាបានបំប៉ននៅវិទ្យាស្ថានជាតិអប់រំពិសេស | ចំនួនអ្នកសម្របសម្រួល និងអ្នកបកប្រែភាសាសញ្ញា១៦នាក់ | | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស | -នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ<br>-នា.ផែនការ<br>-នា.បណ្តុះបណ្តាល | -ថវិកាកម្មវិធី<br>-ដៃគូ | $៦០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស |
| | ៥.៤.១២.២ ផ្តល់អាហាររូបករណ៍ដល់និស្សិតមានពិការភាពដែលរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ(សំលៀកបំពាក់ សម្ភារសិក្សា) | ចំនួននិស្សិតមានពិការភាព ទទួលបានអាហារូបករណ៍ | ១នាក់ទទួលបាន៥០០ដុល្លារក្នុង១ឆ្នាំ<br>២០១៩=៤៦<br>២០២០=៦២<br>២០២១=៧៦<br>២០២២=១១១<br>២០២៣=១៣៩ | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ<br>-នា.ផែនការ<br>-នា.បណ្តុះបណ្តាល | -ថវិកាកម្មវិធី<br>-ដៃគូ | $២១៧.០០០ | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ<br>-នា.ផែនការ |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៤.១៣ រៀបចំសេវាកីឡា សិល្បៈគ្រប់ប្រភេទ និងសេវាផ្សេងទៀតស្របតាមតម្រូវការ | ៥.៤.១៣.១ រៀបចំ និងកែលម្អទីលានកីឡា សិល្បៈ និងផ្តល់សម្ភារសម្រាប់កីឡា និងសិល្បៈដល់សិស្សមានពិការភាពតាមប្រភេទ | ទីលានកីឡា សិល្បៈ និងផ្តល់សម្ភារសម្រាប់កីឡានិងសិល្បៈដល់សិស្សមានពិការភាពតាមប្រភេទនៅ វិទ្យាល័យអប់រំពិសេស | ចំនួនវិទ្យាល័យអប់រំពិសេសទាំង៥ មានទីលាន សម្ភារកីឡា និងសិល្បៈ | X | X | X | X | X | -នា.អប់រំពិសេស<br>-វិ.អពស | -វិទ្យាស្ថានជាតីអប់រំកាយ និងកីឡា<br>-នា.ហិរញ្ញវត្ថុ ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | |
| | ៥.៤.១៣.២ បំប៉នសមត្ថភាពគ្រូកីឡា និងគ្រូសិល្បៈ ស្របតាមប្រភេទពិការភាព | ចំនួនគ្រូកីឡា និងគ្រូសិល្បៈទទួលបានការបំប៉ន | ចំនួនគ្រូកីឡា៥នាក់ និងគ្រូសិល្បៈ៥នាក់នៅវិទ្យាល័យអប់រំពិសេស | X | X | X | X | X | -នា.អប់រំពិសេស<br>វិ.អពស | -វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា<br>-នា.ហិរញ្ញវត្ថុ ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១0,000 | |
| | ៥.៤.១៣.៣ ហ្វឹកហាត់ដល់សិស្សទាំងកីឡា និងសិល្បៈ រួចរៀបចំការប្រកួតកីឡាថ្នាក់ជាតិ និងរៀបចំពិព័រណ៍សិល្បៈដែលសំដែងដោយសិស្សមានពិការភាព | សិស្សមានពិការភាពទាំងបីប្រភេទមានឱកាសប្រកួតកីឡា និងសម្តែងសិល្បៈ | ឱកាសប្រកួតកីឡា និងសម្តែងសិល្បៈចំនួន១ដងក្នុង១ឆ្នាំ | X | X | X | X | X | -នា.អប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា<br>-នា.ហិរញ្ញវត្ថុ ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ***យុទ្ធសាស្ត្រ ៥.៥. ធានាឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស*** | | | | | | | | | | | | | |
| **គោលបំណង ៖** ផ្តល់ឱកាសអប់រំដល់សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យបានរៀនសូត្រ និងចូលរួមគ្រប់សកម្មភាពក្នុងសាលារៀន និងការងារសង្គម។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបានឱកាសរៀនសូត្រ និងចូលរួមគ្រប់សកម្មភាពក្នុងសាលារៀន និងការងារសង្គម។ | | | | | | | | | | | | | |
| ៥.៥.១ អប់រំឪពុកម្តាយ និងសហគមន៍ឱ្យយល់ពីសារប្រយោជន៍នៃការអប់រំកុមារី និងស្ត្រី | ៥.៥.១.១ ផ្សព្វផ្សាយដល់ឪពុកម្តាយ និងសហគមន៍តាមរយៈវិទ្យុ ទូរទស្សន៍ យុទ្ធនាការប្រមូលសិស្សចុះឈ្មោះចូលរៀនមុនបវេសនកាល ទិវាជនពិការជាតិ អន្តរជាតិ បណ្តាញផ្សព្វផ្សាយសង្គម និងការផ្សព្វផ្សាយផ្សេងៗឱ្យយល់ពីសារប្រយោជន៍នៃការអប់រំកុមារី និងស្ត្រី។ | ចំនួន ១ដង ក្នុង ១ឆ្នាំ | ២៥រាជធានី ខេត្ត | X | X | X | X | X | -ក្រសួងព័ត៌មាន<br>-នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-អាជ្ញាធរមូលដ្ឋាន<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៩0.000 | |
| ៥.៥.២ រៀបចំកម្មវិធីលើកកម្ពស់សិទ្ធិទទួលបានសេវាអប់រំសម្រាប់កុមារី និងស្ត្រី | ៥.៥.២.១ ពង្រឹងការអនុវត្តគ្រប់មធ្យោបាយអំពីសិទ្ធិទទួលបានសេវាអប់រំសម្រាប់កុមារី និងស្ត្រី ហើយជ្រើសរើសស្ត្រីមានពិការភាព ០១នាក់ជាជនបង្គោលដែលរស់នៅក្នុងសហគមន៍ | ចំនួនឃុំសង្កាត់ដែលជ្រើសរើសស្ត្រីមានពិការភាពជាជនបង្គោលក្នុងសហគមន៍ | ចំនួន ស្ត្រីមានពិការភាពជាជនបង្គោលក្នុងសហគមន៍ | | X | X | X | X | -ក្រ.កិច្ចការនារី<br>-នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥០,០០០ | |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៥.៣ ផ្តល់ឱ្យសិស្សស្រីមានតម្រូវការអប់រំពិសេសនូវការអប់រំស្តីពីសុខភាព សុវត្ថិភាព និងការការពារ | ៥.៥.៣.១ ពង្រឹងកិច្ចសហការជាមួយមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រូបង្គោល និង ដៃគូដែលមានជំនាញផ្នែកសុខភាព ដើម្បីបំប៉ន សមត្ថភាពដល់អ្នកទទួលខុសត្រូវផ្នែកសុខភាព សុវត្ថិភាព និងការការពារដល់សិស្សស្រីមានតម្រូវការពិសេស | ចំនួនអ្នកចូលរួម និងកិច្ចសហការពីគ្រប់សមាសភាពពាក់ព័ន្ធ ដើម្បីលើកកម្ពស់កុមារី និងស្ត្រីទទួលបានសុខភាព សុវត្ថិភាព និងការការពារ | ការលើកកម្ពស់កុមារី និងស្ត្រីទទួលបានសុខភាព សុវត្ថិភាព និងការការពារ | X | X | X | X | X | -ក្រ.សុខាភិបាល<br>-នា.សុខភាពសិក្សា<br>-នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល<br>- នា.សុខភាពសិក្សា ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១០០,000 | -ក្រ.កិច្ចការនារី<br>-ក្រ.មហាផ្ទៃ<br>-ក្រ.ព័ត៌មាន<br>-ក្រ.សង្គមកិច្ច<br>-ក្រ.សុខាភិបាល<br>-នា.សុខភាពសិក្សា<br>-ដៃគូពាក់ព័ន្ធ |
| ៥.៥.៤ បង្កើនវិធានការដើម្បីការពារកុមារី និងស្ត្រីអំពីអំពើហិង្សា អំពើជួញដូរ និងការរំលោភបំពានគ្រប់រូបភាព | ៥.៥.៤.១ បញ្ជ្រាបច្បាប់ដើម្បីការពារសិទ្ធិកុមារី និងស្ត្រីមានពិការភាពដែលងាយរងគ្រោះដោយអំពើហិង្សា ការជួញដូរ និងការរំលោភបំពានគ្រប់រូបភាព តាមរយៈការផ្សព្វផ្សាយ ស្តីពីការអប់រំបរិយាបន្ន និងការប្រជុំផ្សេងៗគ្រប់រូបភាព | ផ្សព្វផ្សាយ និងការប្រជុំផ្សេងៗគ្រប់រូបភាពការបញ្ជ្រាបច្បាប់សិទ្ធិកុមារី និងស្ត្រី | ចំនួន៣ដង ក្នុង១ឆ្នាំ ផ្សព្វផ្សាយស្តីសិទ្ធិកុមារី និងស្ត្រីការពារពីអំពើហិង្សា អំពើជួញដូរ និងការរំលោភបំពាន | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួង ព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល<br>- នា.សុខភាពសិក្សា ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥0,000 | -ក្រ.កិច្ចការនារី<br>-ក្រ.មហាផ្ទៃ<br>-ក្រ.ព័ត៌មាន<br>-ក្រ.សង្គមកិច្ច<br>-សុខាភិបាល<br>-នា.សុខភាពសិក្សា<br>-ដៃគូពាក់ព័ន្ធ |

| យុទ្ធសាស្ត្រង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៥.៥ ជំរុញកុមារី និងស្ត្រីឱ្យចូលរួមធ្វើការសម្រេចចិត្តក្នុងសង្គម | ៥.៥.៥.១ គាំទ្រ និងជំរុញការផ្តល់សិទ្ធិ ដល់កុមារី និងស្ត្រីស្ថិតក្នុងសេចក្តីត្រូវការពិសេសក្នុងជួរគណៈកម្មការផ្សេងៗក្នុងសាលារៀន និងសហគមន៍ ដើម្បីការចូលរួមការសម្រេចចិត្ត និងអនុវត្ត គ្រប់សកម្មភាព | កុមារី និងស្ត្រីមានការកើនឡើងក្នុងការចូលរួមធ្វើការសម្រេចចិត្ត និង អនុវត្តគ្រប់សកម្មភាព | ចំនួនកុមារី និងស្ត្រី មានការកើនឡើង ក្នុងការចូលរួមធ្វើការសម្រេចចិត្ត និងអនុវត្តគ្រប់សកម្មភាព | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-អាជ្ញាធរមូលដ្ឋាន<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥,០០០ | -នាយកដ្ឋានអប់រំពិសេស<br>-មន្ទីរ ស្រុក<br>-សាលានិងដៃគូ |
| ៥.៥.៦ ធានាឱ្យកុមារី និងស្ត្រីបានចុះឈ្មោះចូលរៀន និងបញ្ចូលសមាសភាពក្នុងសកម្មភាពសាលារៀន និងសង្គម | ៥.៥.៦.១ បង្កើន ការចុះឈ្មោះចូលរៀន កុមារី និងស្ត្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស និងជំរុញឱ្យមានចំនួនកើនឡើងជាលំដាប់នៅក្នុងគណៈកម្មការសាលារៀន និងសង្គម | អត្រាចុះឈ្មោះចូលរៀន និងអត្រាចូលរួមក្នុងសកម្មភាពសាលារៀន និងសង្គម របស់កុមារី និងស្ត្រីស្ថិតក្នុងសេចក្តីត្រូវការពិសេសមានការកើនឡើងជារៀងរាល់ឆ្នាំ | ការចុះឈ្មោះចូលរៀន និងការចូលរួមសង្គម របស់កុមារី និងស្ត្រី មានការកើនឡើង | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងសុខាភិបាល<br>- នា.សុខភាពសិក្សា ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥០,០០០ | -នាយកដ្ឋានអប់រំពិសេស<br>-មន្ទីរ ស្រុក<br>-សាលានិងដៃគូ |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៥.៧ ជានាគាំទ្រលើការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត និងកីឡា ដល់កុមារី និងស្ត្រី | ៥.៥.៧.១ បង្កើនការអនុវត្តកម្មវិធីបំណិនជីវិតងាយៗ និងកីឡា ដល់កុមារី និងស្ត្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស នៅកម្រិតអប់រំមូលដ្ឋាន និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងគ្រឹះស្ថានអប់រំបច្ចេកទេស វិជ្ជាជីវៈ | ភាគរយកុមារី និងស្ត្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស ទទួលបានបំណិនជីវិត និងវិជ្ជាជីវៈកើនឡើង | កុមារីកើនឡើង ១៥% ឆ្នាំក្នុង១ឆ្នាំ ចាប់ពីឆ្នាំ២០១៩<br>ស្ត្រីកើនឡើង ១០% ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ២០២០ | X | X | X | X | X | -ក្រ.សួងការងារ<br>-នា.តម្រង់ទិសវិជ្ជាជីវៈ<br>-នា.មធ្យមសិក្សា<br>-នា.អប់រំពិសេស | -ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងសង្គមកិច្ច<br>-ក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៥,០០០ | -នាយកដ្ឋានអប់រំពិសេស<br>-មន្ទីរ ស្រុក<br>-សាលានិងដៃគូ |
| ៥.៥.៨ ផ្តល់អាហារូបករណ៍ដល់កុមារី និងស្ត្រី ដើម្បីបានចូលរៀនទាំងក្នុង និងក្រៅប្រទេស | ៥.៥.៨.១ បង្កើនអាហារូបករណ៍ ដើម្បីលើកទឹកចិត្តដល់កុមារី និងស្ត្រីបានចូលរៀនក្នុងប្រទេស និងក្រៅប្រទេស | ចំនួនកុមារី និងស្ត្រីទទួលបានអាហារូបករណ៍ក្នុង និងក្រៅប្រទេសមានការកើនឡើង | ១០០នាក់ ឆ្នាំ២០១៩<br>១៥០នាក់ ឆ្នាំ២០២០<br>២០០នាក់ ឆ្នាំ២០២១<br>២៥០នាក់ ឆ្នាំ២០២២<br>៣០០នាក់ ឆ្នាំ២០២៣ | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងការបរទេសអភិវឌ្ឍជនបទ<br>-ក្រ.សង្គមកិច្ច<br>-ក្រ.កិច្ចការនារី<br>-នា.ទំនាក់ទំនង វប្បធម៌ និងអាហារូបករណ៍<br>-នា.ហិរញ្ញវត្ថុ<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៨០,០០០ | |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ***យុទ្ធសាស្ត្រ ៥.៦. អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យស្អាត*** | | | | | | | | | | | | | |
| **គោលបំណង ៖** គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន តម្រូវឱ្យមានហេដ្ឋារចនាសម្ពន្ធ រូបវន្តមានស្រាប់ត្រូវកែសម្រួលឱ្យស្របតាមគំរូស្តង់ដាគំនូសប្លង់សម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស បានប្រើប្រាស់ហេដ្ឋារចនាសម្ពន្ធ រូបវន្ត ដែលមានគំនូសប្លង់តាមបរិបទក្នុងប្រទេស។ | | | | | | | | | | | | | |
| ៥.៦.១ ធានាថាគំនូសប្លង់ថ្នាក់ជាតិត្រូវបានបញ្ចូលក្នុងគោលការណ៍ណែនាំ ត្រួតពិនិត្យគុណភាពសំណង់ | ៥.៦.១.១ ពង្រឹងការអនុវត្តប្រកាសអន្តរក្រសួង លេខ២២៨៨ស អយ.ប្រក ស្តីពីការដាក់ឱ្យអនុវត្តនូវ បទដ្ឋានបច្ចេកទេស ហេដ្ឋារចនាសម្ពន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស និងសេចក្តីណែនាំរបស់នាយកដ្ឋានសំណង់ស្តីពីគំនូសប្លង់ថ្នាក់ជាតិ | មន្ទីរ អយក. ការិ. អយក. គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍បាន អនុវត្តតាមប្រកាសអន្តរក្រសួង និងសេចក្តីណែនាំរបស់នាយកដ្ឋានសំណង់ស្តីពីគំនូសប្លង់ថ្នាក់ជាតិឱ្យមានប្រសិទ្ធភាព | មន្ទីរ អយក. ការិ. អយក. គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនព្រមទាំងដៃគូអភិវឌ្ឍន៍បានអនុវត្តចាប់ពីឆ្នាំ ២០១៩ | X | X | X | X | X | -នា.សំណង់<br>-នា.អប់រំពិសេស | - ក្រ.សង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា (រដ្ឋបាលសិទ្ធិជនពិការ)<br>-ក្រ.រៀបចំដែនដីនគរូបនីយកម្ម<br>-នា. សំណង់<br>-ក្រុមប្រឹក្សាសកម្មភាពជនពិការ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣០,000 | -នា.អប់រំពិសេស<br>-នា.សំណង់<br>-មន្ទីរអយក.<br>-ការិ.អយក. |
| ៥.៦.២ ជំរុញឱ្យគ្រប់គ្រឹះស្ថានសិក្សាមានបន្ទប់ទឹកសមស្របនឹងតម្រូវការជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៦.២.១ ពង្រឹងការកសាង ហេដ្ឋារចនាសម្ពន្ធរូបវន្តបន្ទប់ទឹកសមស្របតាមជនស្ថិតក្នុង សេចក្តីត្រូវការពិសេស និងស្ថិតសិស្ស។ | គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ចំណុះមន្ទីរ អយក. រាជធានីខេត្ត | គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ចំណុះមន្ទីរ អយក ទាំង២៥ | X | X | X | X | X | -នា.សំណង់<br>-នា.អប់រំពិសេស | -នា.សំណង់<br>-គ្រឹះស្ថានបោះពុម្ពចែកផ្សាយ<br>-នា.ទ្រព្យសម្បត្តិ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $២៥.000 | -នា.ហិរញ្ញវត្ថុ<br>-នា.សំណង់<br>-នា.អប់រំពិសេស |

| យុទ្ធសាស្ត្រវែង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៦.២.២ ពង្រឹងការសាងសង់ផ្លូវទៅបន្ទប់ទឹកតាមគំនូសប្លង់ ដោយមាន អក្សរស្ទាបរូបសញ្ញា នៅជិតបន្ទប់រៀននៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន | អាគារចាស់ និងសំណង់ថ្មីត្រូវបានសាងសង់ ជួសជុលកែលម្អហេដ្ឋារចនាសម្ពន្ធរូបវ័ន្ត បន្ទប់ទឹកតាមគំនូសប្លង់ | រាជធានីខេត្តត្រូវសាងសង់ ហេដ្ឋារចនាសម្ពន្ធរូបវ័ន្តបន្ទប់ទឹកតាមគំនូសប្លង់ | X | X | X | X | X | -នា.សំណង់<br>-នា.អប់រំពិសេស | -នា.ហិរញ្ញវត្ថុ<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>- វិទ្យាស្ថានជាតិអប់រំពិសេស<br>-ក្រុមប្រឹក្សាសកម្មភាពជនពិការ<br>-ដៃគូពាក់ព័ន្ធ<br>-ក្រ.សង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា (រដ្ឋបាលសិទ្ធិជនពិការ) | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $២៥,០០០ | -នា.ហិរញ្ញវត្ថុ<br>-នា.សំណង់<br>-នា.អប់រំពិសេស |
| ៥.៦.៣ ធានាថាហេដ្ឋារចនាសម្ពន្ធរូបវ័ន្ត មានស្រាប់ត្រូវបានកែសម្រួលឱ្យស្របតាម គំរូស្តង់ដាគំនូសប្លង់ | ៥.៦.៣.១ ជំរុញការកែសម្រួល ហេដ្ឋារចនាសម្ពន្ធរូបវ័ន្តមានស្រាប់ស្របតាមគំរូ ស្តង់ដាគំនូសប្លង់ដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនស្ថិតនៅក្នុងសេចក្តីត្រូវការពិសេសនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន | គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនចំណុះមន្ទីរអយក. រាជធានីខេត្តមានស្រាប់ ត្រូវបានកែសម្រួល ហេដ្ឋារចនាសម្ពន្ធរូបវ័ន្តតាមគំនូសប្លង់ | គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំង២៥ រាជធានីខេត្តត្រូវបានកែសម្រួល | X | X | X | X | X | -នា.សំណង់<br>-នា.អប់រំពិសេស | -នា.សំណង់ ទ្រព្យសម្បត្តិរដ្ឋ<br>-នា.ហិរញ្ញវត្ថុ<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $២៥.០០០ | -នា.អប់រំពិសេស<br>-នា.សំណង់<br>-មន្ទីរអយក.<br>-ការិ.អយក<br>-នា.ហិរញ្ញវត្ថុ |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៦.៤ ជំរុញការសាងសង់និងគ្រប់គ្រងអន្តេវាសិកដ្ឋាន សម្រាប់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៦.៤.១ ជំរុញការកែសម្រួល ហេដ្ឋារចនាសម្ពន្ធរូបវ័ន្ត និងអន្តេវាសិកដ្ឋាននៅតាមវិទ្យាល័យអប់រំពិសេស ស្របតាមស្តង់ដាគំនូសប្លង់ | អន្តេវាសិកដ្ឋានដែលមាននៅវិទ្យាល័យអប់រំពិសេស ត្រូវបានកែសម្រួល ឬសាងសង់ហេដ្ឋារចនាសម្ពន្ធរូបវ័ន្តតាមគំនូសប្លង់ | អន្តេវាសិកដ្ឋាននៅវិទ្យាល័យអប់រំពិសេសទាំង៥ | X | X | X | X | X | -នា.សំណង់<br>-នា.អប់រំពិសេស | -នា. សំណង់<br>-នា.ហិរញ្ញវត្ថុ<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស<br>-វិ.អពស<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $១០.០០០ | -នា.សំណង់<br>-នាយកដ្ឋានអប់រំពិសេស<br>-នា.ហិរញ្ញវត្ថុ |
| ៥.៦.៥ ធានាឱ្យមានបណ្ណាល័យ បន្ទប់ពិសោធន៍ និងសម្ភារមានស្តង់ដាសមស្របតាមតម្រូវការរបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៦.៥.១ ពង្រឹងការរៀបចំបណ្ណាល័យ បន្ទប់ពិសោធន៍ និងសម្ភារ ឱ្យមានស្តង់ដាសមស្របតាមតម្រូវការរបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | បណ្ណាល័យ បន្ទប់ពិសោធន៍ និងសម្ភារ នៅវិទ្យាល័យអប់រំពិសេសសមស្របតាមតម្រូវការរបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | បណ្ណាល័យបន្ទប់ពិសោធន៍និងសម្ភារៈ នៅវិទ្យាល័យអប់រំពិសេស ទាំង៥ | X | X | X | X | X | -នា.អប់រំពិសេស | -នា.សំណង់ គ្រឹះស្ថានបោះពុម្ពចែកផ្សាយទ្រព្យសម្បត្តិរដ្ឋ<br>-នា.ហិរញ្ញវត្ថុ<br>-នា.បឋមសិក្សា<br>-នា.មធ្យមសិក្សា<br>-វិទ្យាស្ថានជាតិអប់រំពិសេស និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $១៥០,000 | -នា.អប់រំពិសេស<br>-មន្ទីរអេយក.<br>-ការិ.អយក.<br>-នា.ហិរញ្ញវត្ថុ |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៦.៦ ធានាទីលានកីឡា បរិស្ថាន និងផ្លូវនៅក្នុងសាលារៀនឱ្យមានលក្ខណៈសមស្រប | ៥.៦.២.១ កសាង និងកែលម្អទីលានកីឡា បរិស្ថាន និងផ្លូវ នៅក្នុងសាលារៀន ឱ្យមានលក្ខណៈសមស្រប សម្រាប់ជនស្ថិតនៅក្នុងសេចក្តីត្រូវការពិសេស | សាលាដែលមានទីលានកីឡា បរិស្ថាន និងផ្លូវត្រូវបានសាងសង់មានលក្ខណៈសមស្របសម្រាប់ជនស្ថិត ក្នុងសេចក្តីត្រូវការពិសេស | ចំនួនសាលាដែលមានទីលានកីឡា បរិស្ថាននៅវិទ្យាល័យអប់រំពិសេសទាំង៥ | X | X | X | X | X | -នា.អប់រំពិសេស | -នា. សំណង់ ទ្រព្យសម្បត្តិរដ្ឋ<br>-នា.អប់រំកាយ និងកីឡា<br>-នា.ហិរញ្ញវត្ថុ<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>- ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-សហគមន៍ | $៥0,000 | -នា.អប់រំពិសេស<br>-មន្ទីរអយក.<br>-ការិ.អយក.<br>-នា.ហិរញ្ញវត្ថុ |
| ***យុទ្ធសាស្ត្រ ៥.៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន*** | | | | | | | | | | | | | |
| **គោលបំណង ៖** ផ្តល់ការបណ្តុះបណ្តាលគ្រូជំនាញ និងគណៈគ្រប់គ្រងសាលារៀនអប់រំបរិយាបន្ន ស្របតាមការរីកចម្រើន នៃសាកលបច្ចេកវិជ្ជាបរិវត្តកម្ម និងពហុជំនាញផ្នែកអប់រំបរិយាបន្នសម្រាប់គ្រូបង្រៀនអ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** គ្រូ និងគណៈគ្រប់គ្រងសាលារៀនមានគុណវុឌ្ឍិ ក្នុងការបង្រៀនអ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | | | | | | | | | | | | | |
| ៥.៧.១ ផ្តល់អាទិភាពដល់អ្នកសិក្សាមានពិការភាពក្នុងការប្រឡងចូលក្នុងក្របខណ្ឌគ្រូបង្រៀន | ៥.៧.១.១ពង្រឹងការផ្តល់អាទិភាពដល់អ្នកសិក្សាមានពិការភាពប្រឡងចូលក្របខណ្ឌគ្រូបង្រៀន(ផ្តល់ឱកាសស្របតាមអនុក្រឹតលេខ១០៨អនក្រ.បក) | បេក្ខជនមានពិការភាព ទទួលបានក្របខណ្ឌគ្រូបង្រៀនគ្រប់ភូមិសិក្សា | បេក្ខជនមានពិការភាពទទួលបានក្របខណ្ឌគ្រូបង្រៀនគ្រប់ភូមិសិក្សា | X | X | X | X | X | -នា.បណ្តុះបណ្តាល<br>-នា.បុគ្គលិក<br>-នា.អប់រំពិសេស | -នា.ហិរញ្ញវត្ថុ<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.នីតិកម្ម | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | -នា.បណ្តុះបណ្តាល<br>-នា.ហិរញ្ញវត្ថុ |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៧.២ បណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសនៅគ្រប់ភូមិសិក្សា | ៥.៧.២.១ អភិវឌ្ឍឯកសារបណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសនៅគ្រប់ភូមិសិក្សា | ឯកសារបណ្តុះបណ្តាលចំនួន៣ប្រភេទពិការ(គ ថ្លង់ ពិការភ្នែកនិងពិការសតិបញ្ញា) ត្រូវ បានអភិវឌ្ឍ | ឯកសារ ចំនួន៣ប្រភេទពិការ (គ ថ្លង់ ពិការភ្នែក និងពិការសតិបញ្ញា) ត្រូវបានអភិវឌ្ឍ | X | X | X | X | X | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អប់រំពិសេស | -នា.អភិវឌ្ឍកម្មវិធី<br>-នា.បណ្តុះបណ្តាល<br>-វិទ្យាល័យអប់រំពិសេស និងអង្គការដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $១៥០,០០០ | -នា. អប់រំពិសេស<br>-នា.បណ្តុះបណ្តាល<br>-នា.អភិ.កម្មវិធីសិក្សា |
| | ៥.៧.២.២ បណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនជនស្ថិតក្នុងតម្រូវការពិសេស | វគ្គបណ្តុះបណ្តាល និងបំប៉ន នៅវិទ្យាស្ថានជាតិអប់រំពិសេសបំប៉នចំនួន៣ប្រភេទពិការ (គ ថ្លង់ ពិការភ្នែក និង ពិការសតិបញ្ញា) | ចំនួនគ្រូ១០០នាក់ បណ្តុះបណ្តាលរយៈពេល១០ខែ<br>២០១៩=១៨ន<br>២០២០=២០ន<br>២០២១=២០ន<br>២០២២=២២ន<br>២០២៣=២០ន | X | X | X | X | X | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.អប់រំពិសេស<br>-នា.បុគ្គលិក | -នា.អភិវឌ្ឍកម្មវិធី<br>-នា.បណ្តុះបណ្តាល<br>-វិទ្យាល័យអប់រំពិសេស និងអង្គការដៃគូ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០០,០០០ | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា. អប់រំពិសេស<br>-នា.បុគ្គលិក |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៧.៣ ផ្តល់អត្ថប្រយោជន៍បន្ថែមដល់គ្រូដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបង្រៀនសិស្សមានពិការភាព | ៥.៧.៣.១ រៀបចំអនុក្រឹត្យស្តីពីការផ្តល់ប្រាក់លើកទឹកចិត្តបន្ថែម សម្រាប់ភារកិច្ចគ្រូបង្រៀនអប់រំពិសេស | ប្រាក់លើកទឹកចិត្តបន្ថែមសម្រាប់ភារកិច្ចគ្រូបង្រៀនអប់រំពិសេស | ចំនួនគ្រូនៅវិទ្យាល័យអប់រំពិសេសទាំង៥ វិទ្យាស្ថានជាតិអប់រំពិសេស និងថ្នាក់សមាហរណកម្ម | X | X | X | X | X | -នា.អប់រំពិសេស<br>-នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ | -ក្រ.សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រ.មុខងារសាធារណៈ<br>-នា.នីតិកម្ម | -ថវិកាកម្មវិធី<br>-ដៃគូ | $0 | |
| | ៥.៧.៣.២ លើកទឹកចិត្តដល់គ្រូបង្រៀនដែលបានបណ្តុះបណ្តាល ឬបំប៉ន និងមានបទពិសោធន៍ផ្នែកអប់រំពិសេស ឱ្យទទួលបានវិញ្ញាបនបត្រ និងសញ្ញាបត្រ ផ្នែកអប់រំពិសេស | វិញ្ញាបនបត្រ និងសញ្ញាបត្រ ផ្នែកអប់រំពិសេស | ចំនួនគ្រូ១០០ នាក់ទទួលបានវិញ្ញាបនបត្រ និងសញ្ញាបត្រ ផ្នែកអប់រំពិសេស | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រ.មុខងារសាធារណៈ<br>-នា.នីតិកម្ម<br>-នា.បុគ្គលិក រដ្ឋបាល | -ថវិកាកម្មវិធី<br>-ដៃគូ | $៥,០០០ | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស |

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៧.៤ ពង្រឹងសមត្ថភាពគ្រូបង្រៀនជំនាញអប់រំបរិយាបន្នស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងបរិបទសកលភាវូបនីយកម្ម | ៥.៧.៤.២ បញ្ជូនគ្រូបង្រៀនជំនាញអប់រំបរិយាបន្នទៅទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុង និងក្រៅប្រទេសអំពីការប្រើប្រាស់បច្ចេកវិទ្យាទំនើបសម្រាប់បង្រៀនសិស្សមានពិការភាព | ចំនួនគ្រូបង្រៀនជំនាញអប់រំបរិយាបន្ន ទៅទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងនិងក្រៅប្រទេស | គ្រូបង្រៀនជំនាញអប់រំបរិយាបន្នចំនួន៦នាក់ (សម្រាប់ក្រៅប្រទេស) | X | X | X | X | X | នា. អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស | -នា.ហិរញ្ញវត្ថុ<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិទ្យាល័យអប់រំពិសេស<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $១00,000 | -នា. អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស |
| ៥.៧.៥ ពង្រឹងកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូ | ៥.៧.៥.១ អភិវឌ្ឍនិងបញ្ជ្រាបកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូនៅវិទ្យាស្ថានជាតិអប់រំពិសេស វិទ្យាស្ថានជាតិអប់រំ និងគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ចំនួនកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូ នៅវិទ្យាស្ថានជាតិអប់រំពិសេស និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | កម្មវិធីគរុកោសល្យអំពីពិការភាពចំនួន៣ប្រភេទពិការ (ពិការភ្នែក គ ថ្លង់ និងសតិបញ្ញា) | X | X | X | X | X | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.បណ្តុះបណ្តាល<br>-នា.អប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំ និងគ្រប់សាលាគរុកោសល្យ<br>-នា.បណ្តុះបណ្តាល<br>-នា.ពិនិត្យតាមដាននិងវាយតម្លៃ<br>-នា.ធានាគុណភាពអប់រំ | -ថវិកាកម្មវិធី<br>-ដៃគូ | $១00,000 | -នា.អប់រំពិសេស<br>-មន្ទីរអយក.<br>-ការិ.អយក. |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៧.៦ រៀបចំឱ្យមានពហុជំនាញផ្នែកអប់រំបរិយាបន្នសម្រាប់គ្រូបង្រៀនអ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស | ៥.៧.៦.១. រៀបចំឯកសារ បំប៉នសមត្ថភាពកម្មវិធីអប់រំ បរិយាបន្ន សម្រាប់គ្រូបង្រៀនអ្នកសិក្សាស្ថិតនៅក្នុងសេចក្តីត្រូវការពិសេស | គ្រូទទួលបានវគ្គបំប៉នបច្ចេកទេសកម្មវិធីអប់រំបរិយាបន្ន | ចំនួនគ្រូ ៥០០ នាក់ ក្នុង១ឆ្នាំ ទទួលបានវគ្គបំប៉នពហុជំនាញផ្នែកអប់រំបរិយាបន្ន | X | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិទ្យាល័យអប់រំពិសេ<br>-ដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $៦០,000 | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស<br>-មន្ទីរអយក.<br>-ការិ.អយក. |
| ៥.៧.៧ រៀបចំកម្មវិធីបណ្តុះបណ្តាល និងរំក្រឹតការគ្រូ | ៥.៧.៧.៣ អភិវឌ្ឍម៉ោងសម្រាប់កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង និងរំក្រឹតការរយៈពេលខ្លី | កម្មវិធីបណ្តុះបណ្តាល និងរំក្រឹតការរយៈពេល៤ឆ្នាំ | ចំនួនម៉ោងសរុបចំនួន១៣២៨ ម៉ោង | | X | X | X | X | -នា.អប់រំពិសេស<br>-វិទ្យាស្ថានជាតិអប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា. បណ្តុះបណ្តាល<br>-នា.ហិរញ្ញវត្ថុ<br>-នា.បុគ្គលិក<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា | -ថវិកាកម្មវិធី<br>-ដៃគូ | $៨០,000 | -នាយកដ្ឋានអប់រំពិសេស |

*យុទ្ធសាស្ត្រ៥.៨. លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន*

**គោលបំណង ៖** ផ្សព្វផ្សាយនៅកម្រិត ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងសេចក្តីណែនាំស្តីពីការអនុវត្តសម្រាប់គ្រឹះស្ថានសិក្សាឯកជន ដើម្បីលើកកម្ពស់ និងធានាផ្តល់សិទ្ធិ ការគាំទ្រពិសេសក្នុងដំណើរការសិក្សារបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស។

**ផលសម្រេច ៖** អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបានសិទ្ធិ និងការគាំទ្រពិសេសក្នុងដំណើរការសិក្សា។

| យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៨.១ អភិវឌ្ឍយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយនៅកម្រិតថ្នាក់ក្រុង ស្រុក ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ | ៥.៨.១.១ អភិវឌ្ឍយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ តាមរយៈការបំប៉ន ប្រជុំ និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗ | រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និងសហគមន៍ត្រូវបានទទួលការផ្សព្វផ្សាយ | ចំនួនរាជធានី ខេត្ត ទទួលបានការផ្សព្វផ្សាយ | X | | | | | -នា.អប់រំពិសេស<br>-នា.គោលនយោបាយ | -នា.ព័ត៌មាននិងកិច្ចការអាស៊ាន<br>-នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ<br>-មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ. អយកក្រុង ស្រុក ខណ្ឌ ដៃគូពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | -ថវិកាកម្មវិធី<br>-ដៃគូ<br>-អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ<br>- វិស័យឯកជន / សប្បុរសជន | $៣៥,000 | -នា.អប់រំពិសេស<br>-មន្ទីរអេយក.រាជធានី ខេត្ត<br>-ការិ.អយក ក្រុង ស្រុក ខណ្ឌ |
| ៥.៨.២ រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តល្អៗ សម្រាប់គ្រឹះស្ថានសិក្សាទាំងអស់ប្រើប្រាស់ក្នុងពេលផ្សព្វផ្សាយ | ៥.៨.២.១ ប្រមូល និងចងក្រងសេចក្តីណែនាំស្តីពីការអនុវត្តល្អៗ ដូចជា បណ្ណព័ត៌មាន ពាក្យស្លោកសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ប្រើប្រាស់លើបណ្តាញសង្គមផ្សេងៗ | ចំនួនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ទទួលបានចំណេះដឹងនៃការផ្សព្វផ្សាយ | ចំនួនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំង២៥ រាជធានី ខេត្ត | | X | X | X | X | -នា.អប់រំពិសេស | -នា.ព័ត៌មាននិងកិច្ចការអាស៊ាន<br>-នា.បុគ្គលិក<br>-នា.ហិរញ្ញវត្ថុ<br>-មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ. អយកក្រុង ស្រុក ខណ្ឌ ដៃគូពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | -ថវិកាកម្មវិធី<br>-ដៃគូ<br>- វិស័យឯកជន<br>សប្បុរសជន | $១៥,000 | -នា.អប់រំពិសេស<br>-មន្ទីរអេយក.<br>-ការិ.អយក. |

| យុទ្ធសាស្ត្រង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៨.៣ សហការជាមួយគ្រឹះស្ថានសិក្សាឯកជន ដើម្បីលើកកម្ពស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ឱ្យចូលរៀន | ៥.៨.៣.១ ពង្រឹងកិច្ចសហការ រវាងមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និង ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកខណ្ឌជាមួយគ្រឹះស្ថានសិក្សាសារធារណៈ និងឯកជនដើម្បីលើកកម្ពស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ឱ្យទទួលបានសេវាអប់រំប្រកប ដោយគុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត | ចំនួនមន្ទីររាជធានីខេត្តការិយាល័យក្រុងស្រុកខណ្ឌសហការជាមួយគ្រឹះស្ថានឯកជន | មន្ទីរអេយក រាជធានីខេត្តទាំង២៥ និង ការិយាល័យក្រុងស្រុកខណ្ឌទាំង១៩៧ សហការជាមួយគ្រឹះស្ថានឯកជន | | X | X | X | X | -នា.អប់រំពិសេស<br>-វិ.អប់រំពិសេស | -គ្រឹះស្ថានសិក្សាឯកជន<br>-មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ | $២០,០០០ | នា.អប់រំពិសេស មន្ទីរអេយក. ការិ. អេយក. |
| ៥.៨.៤ ធានាផ្តល់សិទ្ធិ និងការគាំទ្រពិសេសក្នុងដំណើរការសិក្សារបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | ៥.៨.៤.១ ជំរុញដល់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន អំពីសិទ្ធិអ្នកសិក្សាមានតម្រូវការពិសេស ក្នុងការចុះឈ្មោះចូលរៀន និងទទួលបានការអប់រំកម្រិតមូលដ្ឋានបានសមស្របតាមតម្រូវការជាក់ស្តែង | ចំនួនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនត្រូវផ្តល់សេវាអប់រំដោយសមធម៌ ដល់អ្នកសិក្សាដែលមានតម្រូវការពិសេស | គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនទាំង២៥ រាជធានី ខេត្ត | X | X | X | X | X | -នា.អប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-វិ.អពស<br>-អយក.រាជធានី ខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>-សាលារៀន និងដៃគូពាក់ព័ន្ធ | -ថវិកាកម្មវិធី<br>-ដៃគូ<br>- វិស័យឯកជន / សប្បុរសជន | $២៥.០០០ | -នា.អប់រំពិសេស<br>-នា.យកដ្ឋានសំណង់<br>-មន្ទីរអេយក.រាជធានី ខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ |

| យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) ១ | ២ | ៣ | ៤ | ៥ | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| *យុទ្ធសាស្ត្រ ៥.៩. ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ* | | | | | | | | | | | | | |
| **គោលបំណង ៖** លើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការអប់រំសម្រាប់ជនដែលមានតម្រូវការពិសេស ហើយលើកទឹកចិត្តមាតាបិតា សហគមន៍ឱ្យយល់ដឹងពីពិការភាព ដើម្បីគាំទ្រជនមានពិការភាព និងគ្រួសារក្រីក្រដែលមានកូនមានពិការភាពក្នុងការបង្កើនមូលនិធិសមធម៌បន្ថែម ដើម្បីជួយដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | | | | | | | | | | | | | |
| **ផលសម្រេច ៖** ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទទួលបានសិទ្ធិ និងការគាំទ្រពីសហគមន៍ ក្នុងការប្រមូលមូលនិធិសមធម៌សង្គមឱ្យសាលារៀនទទួលបានមូលនិធិបន្ថែម ដើម្បីជួយដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស | | | | | | | | | | | | | |
| ៥.៩.១ លើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការអប់រំសម្រាប់ជនមានតម្រូវការអប់រំពិសេស | ៥.៩.១.១ ពង្រឹងការអនុវត្តសិទ្ធិជនពិការ និងផ្សព្វផ្សាយដល់ថ្នាក់រាជធានី ខេត្តថ្នាក់ក្រុង ស្រុក ខណ្ឌ សាលារៀន សហគមន៍ និងមាតាបិតាសិស្សដែលមានកូនមានពិការភាពឱ្យបានទូលំទូលាយ | ចំនួនរាជធានីខេត្តថ្នាក់ក្រុង ស្រុកខណ្ឌ សាលារៀន និងសហគមន៍ អនុវត្តច្បាប់សិទ្ធិជនពិការ | មន្ទីរអេយករាជធានីខេត្ត ទាំង២៥ និងការិយាល័យក្រុង ស្រុកខណ្ឌ ទាំង១៩៧ សាលារៀន និងសហគមន៍ អនុវត្តច្បាប់សិទ្ធិជនពិការ | X | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>-សាលារៀន<br>-មាតាបិតា សិស្ស<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូ | $៣៥,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអេយក.រាជធានី ខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| | ៥.៩.១.២ រៀបចំវេទិកាថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការអប់រំសម្រាប់ជនមានតម្រូវការពិសេស | ចំនួនក្រសួងពាក់ព័ន្ធ នាយកដ្ឋានពាក់ព័ន្ធ មន្ទីរ អយក និងដៃគូពាក់ព័ន្ធចូលរួមរៀបចំវេទិកាថ្នាក់ជាតិ | ក្រសួងពាក់ព័ន្ធចំនួន៥ នាយកដ្ឋានពាក់ព័ន្ធ១០ មន្ទីរអយក២៥ និងដៃគូពាក់ព័ន្ធ ធ្វើរៀងរាល់ឆ្នាំ | X | X | X | X | X | -នា.អប់រំពិសេស | -ក្រសួងពាក់ព័ន្ធ<br>-នា.ពាក់ព័ន្ធ<br>-មន្ទីរ អយក និងដៃគូពាក់ព័ន្ធចូលរួមរៀបចំវេទិកាថ្នាក់ជាតិ | -ថវិកាកម្មវិធី<br>- ដៃគូ | $៥០,០០០ | -នា.អប់រំពិសេស |
| ៥.៩.២ បោះពុម្ពគោលនយោបាយនេះជាអក្សរស្ទាប | ៥.៩.២.១ សហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីស្វែងរកថវិកាបោះពុម្ពគោលនយោបាយស្តីពីការអប់រំបរិយាបន្នជាអក្សរស្ទាប | បោះពុម្ពសៀវភៅគោលនយោបាយជាអក្សរស្ទាប | បោះពុម្ពសៀវភៅគោនយោបាយជាអក្សរស្ទាបចំនួន ១៥០០ ក្បាល | | X | | | | -នា.អប់រំពិសេស | -វិទ្យាស្ថានជាតិអប់រំពិសេស<br>-នា.ហិរញ្ញវត្ថុ<br>-នា.អភិវឌ្ឍកម្មវិធីសិក្សា<br>-វិទ្យាល័យអប់រំពិសេស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | $២២,៥០០ | -នា.អប់រំពិសេស |
| ៥.៩.៣ ពង្រឹងចំណេះដឹង តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តន៍គោលនយោបាយនេះ | ៥.៩.៣.១ អនុវត្តសេចក្តីណែនាំ ស្តីពីតួនាទីនិងភារកិច្ចទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធតាមកម្រិត ថ្នាក់ក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន | អនុវត្តសេចក្តីណែនាំពាក់ព័ន្ធ | ចំនួន ២៥ មន្ទីរអយក.រាជធានីខេត្ត អនុវត្តសេចក្តីណែនាំពាក់ព័ន្ធ | X | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>-សាលារៀន<br>-មាតាបិតា សិស្ស អាណាព្យាបាល សហគមន៍<br>-ដៃគូអភិវឌ្ឍន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | $២៥,០០០ | -នា.អប់រំពិសេស<br>-មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ |

| យុទ្ធសាស្ត្រវង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | អង្គភាពទទួលដឹកនាំ | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា | ពិនិត្យតាមដាន និងវាយតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | | | | |
| ៥.៩.៤ ជំរុញ និងលើកទឹកចិត្តមាតាបិតា សហគមន៍ឱ្យយល់ដឹងពីពិការភាព និងចែករំលែកព័ត៌មាន បទពិសោធន៍ ដើម្បីគាំទ្រជនមានពិការភាព និងគ្រួសារក្រីក្រ ដែលមានកូនមានពិការភាពឱ្យមកទទួលការអប់រំ | ៥.៩.៤.១ ផ្សព្វផ្សាយមាតាបិតា សហគមន៍ ឱ្យយល់ដឹងពីពិការភាព តាមរយៈការចែករំលែកព័ត៌មាន បទពិសោធន៍ ដើម្បីគាំទ្រជនមានពិការភាពនិងគ្រួសារក្រីក្រដែលមានកូនមានពិការភាពឱ្យមកទទួលការអប់រំ | មន្ទីរអេយក. រាជធានី ខេត្ត ការិ.អេយក ស្រុក ខណ្ឌគណៈកម្មការទ្រទ្រង់សាលារៀនគាំទ្រដល់មាតាបិតា គ្រួសារក្រីក្រមានកូនពិការភាពនាំមកទទួលសេវាអប់រំ | មន្ទីរអេយក. រាជធានីខេត្ត ការិ.អេយក ស្រុក ខណ្ឌ គណៈកម្មការទ្រទ្រង់សាលារៀនគាំទ្រដល់មាតាបិតាគ្រួសារក្រីក្រមានកូនមានពិការភាពនាំមកទទួលសេវាអប់រំ | | X | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក.រាជធានីខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>-វិទ្យាល័យអប់រំពិសេស<br>-សាលារៀន<br>-មាតាបិតា សិស្ស<br>-អាជ្ញាធរ សហគមន៍ និងដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | $៥0,000 | -នា.អប់រំពិសេស |
| ៥.៩.៥ បង្កើតមូលនិធិសមធម៌សង្គម ឱ្យសាលារៀនទទួលបានមូលនិធិបន្ថែម ដើម្បីជួយដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។ | ៥.៩.៥.១ ពង្រឹងគណៈកម្មការមូលនិធិសមធម៌សង្គម កំណត់ដោយប្រកាសក្រសួងអប់រំ យុវជន និងកីឡា (៥.៤.១១.១) | ចំនួនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានពង្រឹង | មន្ទីររាជធានីខេត្តទាំង២៥ និង១៩៧ក្រុង ស្រុក ខណ្ឌចាប់ពីឆ្នាំ ២០២១-២០២៣ | | | X | X | X | -នា.អប់រំពិសេស | -មន្ទីរអេយក.រាជធានី<br>-ខេត្ត ការិ.អេយក ក្រុង ស្រុក ខណ្ឌ<br>-វិទ្យាល័យអប់រំពិសេស<br>-សាលារៀន<br>-មាតាបិតា សិស្ស<br>-អាជ្ញាធរ សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | $0 | -នា.អប់រំពិសេស<br>-មន្ទីរអេយក.រាជធានី ខេត្ត<br>-ការិ.អេយក ក្រុង ស្រុក ខណ្ឌ |

## ៦. សរុបចំណាយតាមយុទ្ធសាស្ត្រ

| គម្រោងចំណាយតាមយុទ្ធសាស្ត្រ | ថវិកាចំណាយ |
|---|---|
| យុទ្ធសាស្ត្រ ៥.១. ការអភិវឌ្ឍន៍ក្របខណ្ឌច្បាប់ និងយន្តការ | $៥១,៥០០.០០ |
| យុទ្ធសាស្ត្រ ៥.២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ | $២៦២,០០០.០០ |
| យុទ្ធសាស្ត្រ ៥.៣. អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន | $៣៧០,០០០.០០ |
| យុទ្ធសាស្ត្រ ៥.៤. ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌ | $៤,៥៦១,១០០.០០ |
| យុទ្ធសាស្ត្រ ៥.៥. ធានាឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស | $៤៣០,០០០.០០ |
| យុទ្ធសាស្ត្រ ៥.៦. អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យស្អាត | $៣១៥,០០០.០០ |
| យុទ្ធសាស្ត្រ ៥.៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន | $៥១៥,០០០.០០ |
| យុទ្ធសាស្ត្រ ៥.៨.លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន | $៩៥,០០០.០០០ |
| យុទ្ធសាស្ត្រ ៥.៩.ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ | $១៨២,៥០០.០០ |
| ចំណាយសរុប | $៦,៧៨២,១០០.០០ |

## ៧.ការចំណាយ

ផែនការសកម្មភាពគោលនយោបាយស្តីពីការអប់រំបរិយាបន្ន បានបញ្ចូលការប៉ាន់ប្រមាណចំណាយសម្រាប់សកម្មភាពនៅក្នុងយុទ្ធសាស្ត្រនីមួយៗផងដែរ។ ការប៉ាន់ប្រមាណចំណាយនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ព័ត៌មានសម្រាប់ការអនុវត្តនីតិវិធីប៉ាន់ប្រមាណចំណាយ ដែលធ្វើឡើងដោយនាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ក្នុងការដាក់បញ្ចូលផែនការសកម្មភាពនេះទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន។ នាយកដ្ឋានទទួលខុសត្រូវធានាឱ្យមានថវិកាសម្រាប់ការអនុវត្តសកម្មភាពដែលបានឯកភាពគ្នាតាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីថវិកាជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងអ្នកផ្តល់ជំនួយដទៃទៀត។

ការបង្ហាញតារាងម៉ាទ្រិច បង្ហាញពីការប៉ាន់ប្រមាណជារួម និងស្ថាប័នគាំទ្របែបនេះក៏ផ្តល់លទ្ធភាពឱ្យមានការពង្រឹងការសម្របសម្រួលរវាងនាយកដ្ឋាន និងនាយកដ្ឋាន និងការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយ និងដៃគូនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តផែនការសកម្មភាពនេះផងដែរ។ ការប៉ាន់ប្រមាណចំណាយសម្រាប់រយៈពេល៥ឆ្នាំ (២០១៩-២០២៣) ជួយគាំទ្រក្នុងការកំណត់រកបញ្ហាកង្វះធនធាន ក៏ដូចជាការវិភាគ និងការដាក់អាទិភាពលើធនធានដែលមានផងដែរ។

## ៨.ការត្រួតពិនិត្យ និងការវាយតម្លៃ

ភាពជោគជ័យនៃការអនុវត្តផែនការសកម្មភាពនេះ គឺការបង្កើតនូវដំណើរការពិនិត្យតាមដាន រាយការណ៍ និងវាយតម្លៃដែលមានលក្ខណៈរឹងមាំ។ ដូច្នេះការតាមដាន និងការវាយតម្លៃដោយទម្រង់ដាច់ដោយឡែកពីគ្នា។ ការតាមដាន និងវាយតម្លៃនេះនឹងផ្តល់លទ្ធភាពឱ្យគេអាចកំណត់ដឹងពីវឌ្ឍនភាព និងតម្រូវការចាំបាច់របស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ក្នុងការកំណត់ពីចំណុចខ្វះខាត និងបញ្ហាប្រឈម ។ ការពិនិត្យតាមដាន និងវាយតម្លៃលើផែការសកម្មភាពរួមមាន៖

- របាយការណ៍សកម្មភាពប្រចាំឆ្នាំ សម្រាប់រយៈពេលប្រាំឆ្នាំ
- ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការពិនិត្យឡើងវិញចុងក្រោយ។

ការពិនិត្យឡើងវិញទាំងនេះនឹងធ្វើឡើងតាមការស្រាវជ្រាវ សិក្ខាសាលាថ្នាក់ជាតិ នឹងមានបទបង្ហាញ និងវិភាគលើលទ្ធផលនៃផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន ។

ដំណើរការនេះនឹងផ្តល់លទ្ធភាពឱ្យក្រសួងអប់រំ យុវជន និងកីឡា អាចធ្វើការវាយតម្លៃក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីអនុវត្តផែនការសកម្មភាពអប់រំបរិយាបន្ន និងលិខិតបទដ្ឋាននានាដែលផ្តល់ព័ត៌មានជាមូលដ្ឋានសម្រាប់កែលម្អគោលនយោបាយ និងការវិភាគនានា ក្នុងការផ្តល់សេវាដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។ ព័ត៌មានទាំងនេះនឹងជួយកំណត់រករបៀបប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពបំផុត ដើម្បីជានាសេវាអប់រំសម្រាប់ជនដែលមានតម្រូវការពិសេសគ្រប់គ្នា ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

## ៩. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពគោលនយោបាយស្តីពីការអប់រំបរិយាបន្ន បង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធានាឱ្យជនស្ថិតនៅក្នុងសេចក្តីត្រូវការពិសេសនៅកម្ពុជា ឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ពេញលេញ ដើម្បីក្លាយជាពលរដ្ឋដែលមានជំនាញ អាចចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ និងរួមចំណែកអភិវឌ្ឍសង្គមជាតិ។

ការអនុវត្តផែនការសកម្មភាពគោលនយោបាយនេះ ទទួលបានជោគជ័យ ទាមទារឱ្យមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានសម្ភារបរិក្ខា ដែលជាកត្តាមិនអាចខ្វះបាន។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមនិងជឿជាក់ថា អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ មាតាបិតា សហគមន៍ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមចំណែក ក្នុងការជំរុញ ផ្សព្វផ្សាយ គាំទ្រ និងអនុវត្តផែនការសកម្មភាពគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាព និងជោគជ័យ។

# ពាក្យបំព្រួញ

- **AAR Japan** ៖ សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន
- **CCAMH** ៖ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យ
- **CSES** ៖ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា
- **CRS** ៖ អង្គការកាតូលិក រីលីស សឺវីស
- **CWD** ៖ កុមារមានពិការភាព
- **DAC** ៖ ក្រុមប្រឹក្សាសកម្មភាពជនពិការ
- **DDP** ៖ កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់
- **DDSP** ៖ អង្គការសេវាកម្មអភិវឌ្ឍជនពិការខេត្តពោធិ៍សាត់
- **ECWD** ៖ ការអប់រំកុមារមានពិការភាព
- **IE** ៖ ការអប់រំបរិយាបន្ន
- **EMIS** ៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ
- **ESP** ៖ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- **HCSC** ៖ គណៈកម្មការទ្រទ្រង់មណ្ឌលសុខភាព
- **I/NGOs** ៖ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- **KPF** ៖ អង្គការមូនិធិកុមារពិការ
- **KT** ៖ អង្គការគ្រួសារថ្មី
- **MOEYS** ៖ ក្រសួងអប់រំ យុវជន និងកីឡា
- **MOH** ៖ ក្រសួងសុខាភិបាល
- **MOLVT** ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **MOP** ៖ ក្រសួងផែនការ
- **MOSVY** ៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា
- **NISE** ៖ វិទ្យាស្ថានជាតិអប់រំពិសេស
- **NIS** ៖ វិទ្យាស្ថានជាតិស្ថិតិ
- **NCDP** ៖ មជ្ឈមណ្ឌលជាតិនៃជនពិការ
- **PB** ៖ ថវិកាកម្មវិធី
- **PTTC** ៖ សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្តមានចំនួន ១៨ នៅក្នុងប្រទេសកម្ពុជាសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សា
- **PWD** ៖ ជនមានពិការភាព
- **RTI** ៖ វិទ្យាស្ថានស្រាវជ្រាវត្រីកោណ
- **RSO** ៖ អង្គការសាលារៀនទន្សាយ
- **SED** ៖ នាយកដ្ឋានអប់រំពិសេស
- **SCI** ៖ អង្គការសង្គ្រោះកុមារនៅកម្ពុជា

# សទ្ទានុក្រម

*កុមារមានពិការភាព ៖ជាបណ្តុំបច្ចេកសព្ទដែលរាប់បញ្ចូលទាំងការលំបាកក្នុងការមើល (ខ្សោយចក្ខុវិញ្ញាណ និងពិការភាព) ការលំបាកក្នុងការស្តាប់ (ការលំបាកស្តាប់ និងគ ថ្លង់) ការលំបាកក្នុងការនិយាយ ការលំបាកក្នុងការធ្វើចលនា និងពិការសតិបញ្ញា។

-ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស៖គឺសំដៅដល់ជនទាំងឡាយណាដែលមានពិការភាព ហើយត្រូវការគាំទ្របន្ថែមនិងវិធីសាស្ត្របង្រៀន ដើម្បីសម្រួលដល់ការសិក្សារបស់ពួកគេ។

- ថ្នាក់សមាហរណកម្ម ៖គឺសំដៅដល់ថ្នាក់រៀនដោយឡែកសម្រាប់តែសិស្សមានពិការភាពនៅក្នុងសាលារៀនធម្មតា។ ជាធម្មតាសិស្សដែលមានពិការភាព ដូចជាបញ្ញាស្តាប់ ឬពិការសតិបញ្ញា នឹងត្រូវដាក់ឱ្យរៀនជាមួយគ្នា ដើម្បីមានភាពងាយស្រួលក្នុងការណែនាំ និងរៀនសូត្រ។

- ថ្នាក់អប់រំបរិយាបន្ន ៖គឺសំដៅដល់ការដាក់បញ្ចូលកុមារទាំងអស់ឱ្យរៀនជាមួយគ្នានៅក្នុងប្រព័ន្ធអប់រំទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ ដោយមិនបែងចែកអំពីភេទ អត្តចរិត កាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀត។

- វិទ្យាល័យអប់រំពិសេស ៖សាលារៀនសម្រាប់តែកុមារមានពិការភាព។ ការរៀនក្នុងសាលានេះកុមារមានពិការភាពមានឱកាសតិចតួច ឬមិនមានឱកាសសោះក្នុងការទំនាក់ទំនងជាមួយសិស្សមានការអភិវឌ្ឍធម្មតា

- អវៈយវៈសិប្បនិម្មិត ៖ឧបករណ៍ដើម្បីជំនួយអវៈយវៈដែលបាត់បង់

-ឧបករណ៍ជំនួយ ៖គឺសំដៅដល់គ្រឿងប្រដាប់ពិសេសសម្រាប់សម្រួលការលំបាករបស់កុមារមានពិការភាព។ ឧទាហរណ៍៖ រទេះរុញ ឬឈើច្រត់ជួយសម្រួលដល់ការធ្វើដំណើររបស់កុមារដែលមានបញ្ហាចលនា និងវ៉ែនតាជួយសម្រួលដល់កុមារដែលមានបញ្ហាមើល។

- ឧបករណ៍ជំនួយក្នុងការធ្វើចលនា ៖ឧបករណ៍សម្រាប់ជួយមនុស្សដែលមានការលំបាកក្នុងការបន្លាស់ទី។

- ឧបករណ៍ជំនួយរាងកាយ ៖ឧបករណ៍ជំនួយសម្រាប់អ្នកដែលមានផ្នែកនៃរាងកាយខ្សោយដូចជា ឈើច្រត់សម្រាប់ជនមានពិការភាព។

ឧបត្ថម្ភថតចម្លងដោយៈ

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)